01072059

E1/270.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Apr-2015, 09:25
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ១៣:៣៤នាទី**

**សវនាការលើកទី២៥១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍(*Judge Claudia FENZ*)

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ែន៍
(*Judge Jean-Marc LAVERGNE*)

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
(*Judge Martin KAROPKIN*)

**ក្រឡាបញ្ជីសាលាដំបូង៖**

*កញ្ញា ជា ស៊ីវហ័ង*

*កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី*
(*Ms. Maddalena Ghezzi*)

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
(*Mr. Vincent De Wilde d ESTMAEL*)

លោក សេង ប៊ុនឃាង

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

**លោក នួន ជា**

**លោក ខៀវ សំផន**

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

លោក សួន វិសាល

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឹស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក **ឡោ ជុនធី**

**លោក វ៉េន ពៅ**

**លោកស្រី ទី ស្រីនណា**

**លោកស្រី ជេត វណ្ណលី**

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍***(Ms.Marie GUIRAUD)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

**លោក អ៊ុច អរុណ**

លោកស្រី ស្វ សុទ្ធាវី

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោក វ៉ាន់ សឿន ហៅ ស៊ាន់ (2-TCW 847) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក វ៉ាន់ សឿន ហៅ ស៊ាន់** (2-TCW 847)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................................ទំព័រ ៣

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី ....................................................ទំព័រ ៦

# កិច្ចដំណើរការនីតិវិធី

[១៣:៣៤:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-847។

ក្រឡាបញ្ជីសវនាការកញ្ញា *ជា ស៊ីវហ៉ង* ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការរសៀលនេះ។

**ក្រឡាបញ្ជី៖**

**សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែលោកស្រី អង់តា ហ្គីសសេ មេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ សំផន អវត្តមានដោយលោកស្រីមានធុរៈផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះមានរហស្សនាម 2-TCW-847។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺ លោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ លោកមានមេធាវីប្រឹក្សា គឺលោកមេធាវី ម៉ម រិទ្ធា។ សាក្សីនិងមេធាវីប្រឹក្សាមានវត្តមានៅបន្ទប់រង់ចាំៗការកោះហៅពីពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។**

[១៣:៣៦:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា *ស៊ីវ ហ៉ង*។ បាទ មុននឹងកោះហៅសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់លោក នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជន

ជាប់ចោទ នួន ជា ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានជម្រាបអំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃដំណើរការលើរូបខ្លួនឡើយ។

[១៣:៣៨:០២]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យថែទាំព្យាបាលសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះខ្លាំង និងវិលមុខ ហើយបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះសម្រេចយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលថ្ងៃនេះ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការរួមទាំងមេធាវីប្រឹក្សាសាក្សីផង។

*(សាក្សីនិងមេធាវីប្រឹក្សាចូលក្នុងបន្ទប់សវនាការ)*

[១៣:៤០:៤៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

បាទ សួស្តីលោកសាក្សី!

**ស៖** តើលោកឈ្មោះអ្វី?

**លោក វ៉ាន់ សឿន៖**

**ឆ៖** ខ្ញុំបាទឈ្មោះ វ៉ាន់ សឿន។

**ស៖** ឈ្មោះ វ៉ាន់ សឿន! អ៊ីចឹងមែនទេ? ចុះ ឈ្មោះ ស៊ាន់ ហ្វឹង ឈ្មោះអ្នកណាគេ?

**ឆ៖** បាទ ឈ្មោះខ្ញុំដែរ បាទ។

**ស៖** ឈ្មោះ ផ្លូវការរបស់លោក ដែលលោកប្រើប្រាស់សព្វថ្ងៃនេះ ឈ្មោះអ្វីពិតប្រាកដ?

**ឆ៖** វ៉ាន់ សឿន។

**ស៖** អ៊ីចឹង ឈ្មោះ ស៊ាន់ ហ្វឹង គឺឈ្មោះហៅក្រៅទេ។ អ៊ីចឹងមែនដែរទេ?

**ឆ៖** បាទ។

**ស៖** លោក សឿន តើលោកកើតនៅថ្ងៃ ខែឆ្នាំណា? លោកអាចប្រាប់អង្គជំនុំជម្រះបានដែរទេ?

**ឆ៖** ឆ្នាំ ១៩៥៩។

**ស៖** អរគុណលោក វ៉ាន់ សឿន។ តើលោកមានទីកន្លែងកំណើត នៅទីកន្លែងណា?

**ឆ៖** ភូមិជ្រៃ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** ចុះទីលំនៅសព្វថ្ងៃតើលោក រស់នៅទីកន្លែងណា?

**ឆ៖** ភូមិជ្រៃ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** លោកប្រកបមុខរបររកស៊ីធ្វើអ្វី សព្វថ្ងៃនេះ?

**ឆ៖** ធ្វើស្រែ។

**ស៖** តើលោកអាចប្រាប់អង្គជំនុំជម្រះ បានដែរទេ ថាឪពុកបង្កើតរបស់លោកឈ្មោះអ្វី? ហើយម្តាយបង្កើតគាត់ឈ្មោះអ្វី?

**ឆ៖** ឪពុកឈ្មោះ ម៉ៅ សែម ម្តាយឈ្មោះ ណាំ ផាត់។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអ្វី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធឈ្មោះ ម៉ម យី។ មានកូនប្រាំបីនាក់។

**ស៖** បាទ អរគុណ លោក វ៉ាន់ សឿន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ អម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោក មិនមាន ឪពុក ម្ដាយ បុព្វញាតិ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃប្រពន្ធ ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ទេ។ តើពិតមែនដែរទេ?

**ឆ៖** បាទ។

**ស៖** ហើយរបាយការណ៍ដដែលថាលោកបានស្បថរួចហើយ មុននឹងលោកចូលមកកាន់កន្លែងផ្ដល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះ។ តើពិតមែនដែរទេ?

**ឆ៖** បាទ។

**ប្រធានអង្គជំនុំ៖**

លោក វ៉ាន់ សឿន ក្នុង -- យើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចរបស់លោក ក្នុងនាមលោកជាសាក្សី អំពីសិទ្ធិ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ចំពោះមុខអង្គជំនុំជម្រះនេះ។ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអំណះអំណាងណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយ ឬការអះអាងរបស់លោកនោះនាំឲ្យលោកត្រូវទទួលប្រឈម និងទទួលរងនូវការចោទប្រកាន់។

អំពីករណីយកិច្ចលោក សឿន ក្នុងនាមលោកជាសាក្សី ត្រូវផ្ដល់សក្ខីកម្ម នៅក្នុងកិច្ចដំណើរការសវនាការ នៅចំពោះមុខអង្គជំនុំជម្រះលោកត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក លើកលែងតែសំណួរដែលនាំឲ្យចម្លើយតបរបស់លោកឬក៏ការធ្វើអត្ថាធិប្បាយណាមួយឬច្រើនរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយក្នុងនាមលោកជាសាក្សី ត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ធ្លាប់មានបទពិសោធន៍ធ្លាប់ជួបប្រទះ ឬបានធ្វើការសង្កេត ដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរទៅលោក។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក វ៉ាន់ សឿន តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមកប៉ុន្មានឆ្នាំកន្លង

មកនេះ? ហើយប្រសិនបើមាន តើធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណាខ្លះ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ធ្វើបានពីរដង។ នៅផ្ទះម្ដង នៅតុលាការហ្នឹងម្ដង។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកកាន់ចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ ក្នុងហ្នឹងក្រែងលោមានភ្លេចខ្លះ ព្រោះវាយូរឆ្នាំណាស់ដែរហើយ តាំង២០០៧។ បាទ រហូតដល់២០១៥នេះ ក្រែងលោខ្ញុំអាចមានភ្លេចខ្លះ។

**ស៖** បាទ លោកមានដែលបានពិនិត្យមើល ឬបានអានដែរទេ?

**ឆ៖** បាទ បានអាន។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្ដាប់ចម្លើយដែលលោកបានអាន ឬក៏បានពិនិត្យមើលដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ ឬក៏វាស៊ីចង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ។

[១៣:៤៧:២៧]

**ស៖** បាទ ហើយឥឡូវនេះលោកមកឆ្លើយចំពោះមុខអង្គជំនុំជម្រះ លោកបានស្នើសុំឲ្យមានវត្តមានមេធាវីប្រឹក្សា។ ឥឡូវនេះ អង្គជំនុំជម្រះបានចាត់តាំងមេធាវីប្រឹក្សាមួយរូប ដើម្បីជួយលោកនៅក្នុងការឆ្លើយទៅនឹងសំណួរដូចយើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចរបស់លោកបានរួចហើយ អំពីសិទ្ធិក្នុងការដែលមិនឆ្លើយ -- ឆ្លើយតបទៅនឹងសំណួរចំពោះសំណួរណាដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយលោកបានពិគ្រោះ ពិភាក្សាជាមួយនឹងមេធាវីប្រឹក្សាហើយឬនៅ?

**ឆ៖** បាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយលោកមេធាវីប្រឹក្សាអាចប្រាប់ឈ្មោះរបស់លោកបានដែរឬទេ? ឈ្មោះនិងអត្តលេខ ហើយនិងអាសយដ្ឋានការិយាល័យរបស់លោកប្រតិបត្តិការសព្វថ្ងៃនេះ?

**លោក ម៉ម រិទ្ធា៖**

បាទ សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទមេធាវីប្រឹក្សាឈ្មោះ ម៉ម រិទ្ធា មានអត្តលេខ៦១៩ មានការិយាល័យស្ថិតនៅផ្ទះលេខ១៥០អា ផ្លូវ១៥០ សង្កាត់បឹងព្រលឹត រាជធានីភ្នំពេញ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណបាទ។

បាទ ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយពេលមួយថ្ងៃ ហើយនិងមួយវគ្គនៃសវនាការ។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

[១៣:៥០:១១]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វ៉ាំងសង់ដេវីល ខ្ញុំនឹងសួរសំណួរលោក តាំងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញានៅរសៀលនេះនិងស្អែកព្រឹក។ ប្រសិនបើលោកមិនយល់សំណួរទេ សូមលោកប្រាប់ខ្ញុំ ខ្ញុំនឹងសួរឡើងវិញ។ ប្រសិនបើលោកមិនដឹងទេ លោកកុំឆ្លើយស្មាន សូមលោកប្រាប់ថា លោកមិនដឹង។ ខ្ញុំនឹងសួរសំណួរដំបូង ពាក់ព័ន្ធទៅនឹងអតីតកាលរបស់លោក គឺអ្វីដែលលោកបានធ្វើនៅមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។

**ស៖** នៅចន្លោះឆ្នាំ១៩៧០ និង៧៤ គឺលោកមានអាយុប្រហែល១១ ទៅ១៥ឆ្នាំ។ តើលោកធ្វើអ្វីដែរ នៅសម័យនោះ គឺនៅចន្លោះពីឆ្នាំ១៩៧០ ទៅដល់ឆ្នាំ១៩៧៤? ហើយនៅកន្លែងណាដែរ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** ខ្ញុំបាទ ឆ្នាំ១៩៧០ ដល់៧៤ ខ្ញុំនៅជាមួយឪពុកម្តាយ។ ចុងឆ្នាំ៧៤ រហូតដល់៧៥ បានកង

ឈ្លបឃុំបានចាប់ខ្ញុំទៅធ្វើជាឈ្លប ឈ្លបឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ បន្តមកទៀត គឺគេបញ្ជូនខ្ញុំទៅកងស្រុក នៅស្រុកត្រាំកក់ ទីរួមខេត្តតាកែវ បាទ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយសំណួរនូវអ្វីដែលខ្ញុំចង់សួរទៅហើយ ខ្ញុំចង់ឲ្យលោកឆ្លើយតែទៅនឹងសំណួរដែលខ្ញុំសួរប៉ុណ្ណោះ។ នៅចន្លោះឆ្នាំ៧០ ទៅដល់ឆ្នាំ១៩៧៥ តើឃុំលាយបូរនោះ ស្ថិតនៅក្នុងស្រុក និងតំបន់ណាដែរ?

**ឆ៖** បាទ ឃុំលាយបូរ ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ បាទ។

**ស៖** តើស្រុកត្រាំកក់ហ្នឹង មានឈ្មោះជាលេខទេ? ហើយឈ្មោះតំបន់ និងឈ្មោះភូមិភាគហ្នឹង តើមានជាលេខទេ? បើមានសូមលោកប្រាប់។

**ឆ៖** បាទ ស្រុកត្រាំកក់មាន គេហៅតំបន់ -- ស្រុក១០៥ តំបន់១៣។

[១៣:៥២:៥៧]

**ស៖** សូមអរគុណ។ លោកបានថា -- លោកបានឆ្លើយថា នៅចុងឆ្នាំ៧៤ លោកបានចូលធ្វើជាទាហាន។ តើលោកចូលដោយស្ម័គ្រចិត្ត ឬក៏គេចាប់បង្ខំឲ្យលោកចូលធ្វើជាទាហាន?

**ឆ៖** បាទ កាលជាដំបូងគេឲ្យខ្ញុំទៅសែងរបួស អស់ពីសែងរបួស គេចាប់យកទៅតែម្ដង។ ខ្ញុំក៏រត់ចេញមួយវគ្គ បាទ ហើយគេចាប់យកទៅទៀត។

**ស៖** លោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺលេខ E319.1.33 នៅចម្លើយទី៤ ខ្ញុំសូមដកស្រង់៖ "គេបានបង្ខំឲ្យខ្ញុំចូលធ្វើទ័ពនៅខាងខ្មែរក្រហម។ ដំបូងគេឲ្យខ្ញុំធ្វើជាអ្នកសែងអ្នករបួសនៅសមរភូមិលន់នល់។ ក្រោយមកគេឲ្យខ្ញុំទៅធ្វើឈ្លបឃុំលាយ-បូរ"។ ហើយនៅចម្លើយទី៥ លោកឆ្លើយថា៖ "ខ្ញុំគេឲ្យធ្វើនៅក្នុងកងទ័ពស្រុក ស្រុកត្រាំកក់"។ សូមបញ្ចប់ការដកស្រង់។ តើលោកអាចឆ្លើយបញ្ជាក់បានទេ ថាដំបូងគឺលោកចូលធ្វើជាឈ្លបឃុំសិន បន្ទាប់មកបានលោកទៅធ្វើជាទ័ពស្រុក គឺនៅស្រុកលាយបូរហ្នឹង?

**ឆ៖** មុនដំបូង គេឲ្យខ្ញុំធ្វើឈ្លបឃុំសិន។ ជាបន្តទៀត បានគេបញ្ជូនឡើងទៅស្រុក បាទ។

**ស៖** អ៊ីចឹង គឺលោកមិនធ្លាប់ស្ថិតនៅក្នុងកងពលណាមួយទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅរយៈពេលចន្លោះពីថ្ងៃទី១៧ មេសា ៧៥ រហូតដល់ពេលដែលគេចាត់តាំងលោកឲ្យទៅធ្វើនៅក្រាំងតាចាន់។ ខ្ញុំនឹងអានចម្លើយរបស់លោក។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមមេត្តាអនុញ្ញាតផ្តល់ជូននូវកំណត់ហេតុដែលគាត់បានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដើម្បីឱ្យគាត់អាចពិនិត្យមើលនូវសំណួររបស់ខ្ញុំបាន។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១៣:៥៥:៥៦]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នៅក្នុងកំណត់ហេតុទី២ គឺ E319.1.33 ខ្ញុំសូមអានសំណួរចម្លើយទី៨។ "សំណួរទី៨៖ បន្ទាប់មកនៅឆ្នាំ១៩៧៥ តើគេឱ្យលោកធ្វើអ្វីទៀត? ចម្លើយទី៨៖ នៅឆ្នាំ១៩៧៥ គេឱ្យខ្ញុំឈរជើងនៅទីរួមខេត្តតាកែវ។ ចម្លើយទី៩៖ លោកធ្វើជាកងទ័ព ហើយមានការវ៉ៃប្រហារគ្នាយ៉ាងខ្លាំង។ ខ្មែរក្រហមមិនទាន់វ៉ៃបានភ្នំពេញនោះទេ ហើយខ្ញុំត្រូវគេឱ្យសែង -- ខ្ញុំមិនត្រូវបានគេឱ្យសែងអ្នករបួសទៀតទេ។ នៅដើមឆ្នាំ៧៥ នៅពេលដែលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេស ខ្ញុំត្រូវបានគេឱ្យមកឈរជើងនៅស្រុកត្រាំកក់ ក្នុងឋានៈជាទាហានដដែល"។ សូមបញ្ចប់ការដកស្រង់។ លោកអាចប្រាប់បានទេថា ទីរួមខេត្តតាកែវ មានទីតាំងនៅកន្លែងណា? ហើយអ្នកណាខ្លះជាមេដឹកនាំខេត្តតាកែវ នៅដើមឆ្នាំ១៩៧៥ មុនពេលវាយយកទីក្រុងភ្នំពេញបាននោះ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** កាលណោះ ខ្ញុំអត់បានដឹងទេបាទ។ មិនដឹងអ្នកណាប្រធានតំបន់ ឬប្រធានខេត្តទេ។

**ស៖** អ៊ីចឹងមន្ទីរ -- ទីរួមខេត្តតាកែវហ្នឹងស្ថិតនៅកន្លែងណាមុនពេលដែលវាយយកតាកែវបានហ្នឹង?

**ឆ៖** ទីរួមខេត្តតាកែវស្ថិតនៅស្រុកទ្រាំង និងស្រុកដូនកែវបច្ចុប្បន្ន។

**ស៖** តើទីរួមខេត្តមានចម្ងាយឆ្ងាយពីស្រុកត្រាំកក់ទេ?

**ឆ៖** ព្រំប្រទល់ទល់នឹងផ្លូវរថភ្លើងស្ពានអូរចំបក់ទៅកើត។

**ស៖** នៅក្នុងឯកសារដដែល គឺនៅចម្លើយទី១០ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ សំណួរគេសួរថា៖ "ពេលដែលលោកឈរជើងនៅស្រុកត្រាំកក់ តើគេឱ្យលោកធ្វើអ្វីខ្លះ? ចម្លើយទី១០៖ គេឱ្យខ្ញុំ

រត់សំបុត្រ"។ សូមបញ្ចប់ការដកស្រង់។ ចំពោះខ្ញុំៗដូចជាមិនសូវយល់ច្បាស់ទេ ព្រោះថាលោកៗមានតួនាទីជានីរសាររួចទៅហើយនៅទីរួមខេត្តតាកែវ ឬក៏ស្រុកត្រាំកក់។ ឬមួយក៏លោកធ្វើជានីរសារហ្នឹងនៅពេលដែលលោកទៅដល់ក្រាំងតាចាន់រួចទៅហើយទេ? ខ្ញុំចង់ដឹងថាពីមុនទៅដល់ក្រាំងតាចាន់ហ្នឹងលោកធ្លាប់ជានីរសារទេ?

[១៣:៥៩:១៨]

**ផ៖** បាទ កាលពីមុនហ្នឹង ខ្ញុំធ្លាប់នៅនីរសារកងស្រុក។ ដល់គេបញ្ជូនខ្ញុំមកមន្ទីរក្រាំងតាចាន់គេឲ្យខ្ញុំធ្វើនីរសារដដែល។

**ស៖** នៅពេលដែលលោកជានីរសារស្រុក តើលោកយកសំបុត្រទៅឲ្យ -- ពីអ្នកណា ហើយទៅឲ្យអ្នកណា? ហើយទៅឲ្យកន្លែងណាខ្លះ?

**ផ៖** បាទ ខ្ញុំទទួលពីប្រធានមន្ទីរក្រាំងតាចាន់ទៅឲ្យនៅកន្លែងនីរសារស្រុកត្រាំកក់ នៅផ្សារអង្គរកា។

**ស៖** ខ្ញុំជឿថាលោកនិយាយនេះ គឺលោកនិយាយនៅពេលដែលលោកនៅក្រាំងតាចាន់ គឺលោកទទួលសំបុត្រ ហើយលោកយកទៅឲ្យស្រុក។ ប៉ុន្តែខ្ញុំនិយាយនេះ គឺខ្ញុំនិយាយមុនពេលដែលគេចាត់តាំងឲ្យលោកទៅធ្វើនៅក្រាំងតាចាន់ គឺលោកឆ្លើយថាលោកធ្វើជានីរសារស្រុក មុនពេលទៅក្រាំងតាចាន់។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅពេលដែលលោកនៅស្រុកត្រាំកក់នោះ លោកយកសំបុត្រទៅឲ្យអ្នកណា?

**ផ៖** បាទ ការនិយាយដូចថាបកក្រោយបន្តិច ប៉ុន្តែខ្ញុំសូមបញ្ជាក់ថែមថា ក្នុងកន្លែងនេះមុនដំបូងខ្ញុំទៅកងស្រុក តែគេបញ្ជូនខ្ញុំមកកាន់កន្លែងមន្ទីរក្រាំងតាចាន់។ កាលណោះខ្ញុំក៏នៅនីរសារដែរ នីរសារនៅកងស្រុកហ្នឹង។ បាទហើយខ្ញុំមកនៅមន្ទីរក្រាំងតាចាន់ ក៏គេឲ្យខ្ញុំធ្វើជានីរសារដែរបាទ។

**ស៖** បាទ សូមអរគុណ។ អ្នកណាជាចៅហ្វាយស្រុកត្រាំកក់ នៅចន្លោះមេសា ឆ្នាំ៧៥ ឬក៏ក្រោយឆ្នាំ១៩៧៥?

**ផ៖** បាទ ចៅហ្វាយស្រុកត្រាំកក់មុនដំបូងគឺ តាជឹម។ បន្ទាប់មក តាជឹម ក៏ផ្លាស់ទៅនៅខេត្តកំពង់ចាម ចម្ការកៅស៊ូ ក៏គេយកគណៈស្រុកថ្មីឈ្មោះ តាសាន។

[១៤:០២:១៥]

**ស៖** តើ តាជឹម ហ្នឹងគាត់ឡើងជាគណៈស្រុកនៅពេលណា -- នៅឆ្នាំណា? ហើយគាត់ចេញពីស្រុកត្រាំកក់ហ្នឹងនៅឆ្នាំណា?

**ឆ៖** តាជឹម ហ្នឹងគាត់ចេញចន្លោះពេលពីឆ្នាំ៧៥មក៧៦, ៧៧ទៅហើយ ខ្ញុំក៏មិនបានដឹងច្បាស់ដែរ ពីព្រោះចៅហ្វាយស្រុកគេផ្លាស់អត់ដែលប្រាប់យើង បាទ។

**ស៖** លោកបានឆ្លើយនូវចំពោះមុខអ្នកស៊ើបអង្កេតថា ខុម ជាគណៈស្រុក ជាចៅហ្វាយស្រុក។ នៅក្នុងកំណត់ហេតុរបស់លោកគឺ E319.1.33 លោកបានឆ្លើយនូវចម្លើយ១៤៦ទៅដល់១៥៤។ លោកឆ្លើយថា "កូនស្រី តាម៉ុក ឈ្មោះ ខុម បានដឹកនាំកិច្ចប្រជុំមួយនៅអង្គរកាក្នុងវត្ត ហើយនៅពេលនោះគាត់និយាយឱ្យផ្សឹកព្រះសង្ឃ"។ តើលោកមានចាំទេថា លោកបាននិយាយអំពីកិច្ចប្រជុំមួយនៅអង្គរកា?

**ឆ៖** បាទ ចាំ។ នៅចន្លោះដែលចៅហ្វាយស្រុកក្រោយពី តាជឹម ហ្នឹងគាត់ឆ្លងផុតទៅគឺ ចែខុម មែន។ បាទ ខ្ញុំភ្លេចត្រង់ចន្លោះហ្នឹងដែរ បាទសូមអរគុណ សូមទោស។

**ស៖** សូមអរគុណ។ ខ្ញុំនឹងអានចម្លើយរបស់លោក ដើម្បីរំឭកការចងចាំរបស់លោក គឺនៅក្នុងឯកសារលេខ E319.1.33 ជាពិសេសគឺពាក់ព័ន្ធនឹងកាលបរិច្ឆេទ។ "ចម្លើយ១៤៦៖ ខ្ញុំបានឃើញគេផ្សឹកព្រះសង្ឃ -- ចម្លើយ១៤៧៖ ខ្ញុំបានឃើញគេផ្សឹកព្រះសង្ឃនៅវត្តអង្គរកាក្នុងស្រុកត្រាំកក់ ប្រហែលជានៅចុងឆ្នាំ១៩៧៥។ ចម្លើយ១៤៨៖ គេរៀបចំការប្រជុំ ហើយគេផ្សឹកតែម្តង។ នៅពេលនោះគេផ្សឹកព្រះសង្ឃប្រហែលជា៣០ទៅ៤០អង្គ។ សំណួរ៖ តើអ្នកណាជាអ្នកដឹកនាំការប្រជុំនៅពេលនោះ? ចម្លើយ១៤៩៖ កូនរបស់ តាម៉ុក ជាចៅហ្វាយស្រុក គឺជាអ្នកដឹកនាំការប្រជុំ។ ចម្លើយ១៥០៖ ឈ្មោះ ខុម ជាមនុស្សស្រី ជាចៅហ្វាយស្រុកត្រាំកក់មុនគេបង្អស់ គឺមុនចៅហ្វាយស្រុកឈ្មោះ ជឹម ទៅទៀត។ ខុម ជាប្រពន្ធរបស់តាមុត ដែលជាប្រធានកងពលលេខ២។ សំណួរ៖ ហេតុអ្វីបានជាលោកដឹងអំពីរឿងផ្សឹកព្រះសង្ឃនេះ? ចម្លើយ១៥១ គេបានឱ្យខ្ញុំយកសំបុត្រទៅឱ្យគេ។ ពេលនោះ ខ្ញុំក៏ឃើញគេផ្សឹកព្រះសង្ឃ។ ចម្លើយ១៥២៖ គេនិយាយថា គេមិនត្រូវឱ្យមានព្រះសង្ឃនោះទេ ហើយគេបានរៀបចំខោអាវខ្មៅមួយកំប្លេម្នាក់សម្រាប់ព្រះសង្ឃទាំងអស់នោះ គេមិនបានផ្សឹកព្រះសង្ឃតាមបែបសាសនានោះទេ។ សំណួរ៖ តើកូនរបស់តាម៉ុក ជាអ្នកឡើងនិយាយប្រាប់ព្រះសង្ឃនៅពេលប្រជុំនោះមែនទេ? ចម្លើយ១៥៤៖ បាទ កូនរបស់តាម៉ុក ជាអ្នកឡើងនិយាយ។" សូមបញ្ចប់ការដកស្រង់។

[១៤:០៦:០៩]

នៅក្នុងចម្លើយទាំងនេះ គឺលោកបាននិយាយយ៉ាងច្បាស់ថា ខុម ជាចៅហ្វាស្រុកត្រាំកក់មុនដំបូងគេបង្អស់ ហើយគាត់ជាចៅហ្វាយស្រុកហ្នឹង គឺមុនឈ្មោះតាជឹម ហ្នឹងទៅទៀត។ អ៊ីចឹងនៅពេលដែលខ្ញុំអានអ៊ីចឹង តើធ្វើឱ្យលោកចងចាំឡើងវិញទេ?

**ឆ៖** បាទ។

**ស៖** នៅពេលដែលលោកឆ្លងកាត់តាមវត្តអង្គរកា គឺនៅចុងឆ្នាំ៧៥ ហើយលោកក៏បានឃើញអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងវត្តនោះ តើនៅពេលនោះ គឺលោកទៅមន្ទីរស្រុកអង្គរកា ឬក៏យ៉ាងម៉េច? ឬមួយក៏តើហេតុអ្វីបានជាពេលនោះ លោកបានចូលរួមនៅក្នុងការប្រជុំហ្នឹង លោកគ្រាន់តែដើរកាត់ ហើយឃើញគេប្រជុំផ្សឹកព្រះសង្ឃហ្នឹង ឬក៏លោកត្រូវបានគេកោះឲ្យទៅចូលរួមនៅក្នុងកិច្ចប្រជុំហ្នឹងដែរ?

**ឆ៖** បាទ ក្នុងពេលហ្នឹង ខ្ញុំឮគេនិយាយទេបាទ។

**ស៖** លោកបាននិយាយថា គេឲ្យខ្ញុំយកទៅសំបុត្រទៅទីនោះ ហើយពេលនោះក៏បានឃើញគេផ្សឹកព្រះសង្ឃ។ អ៊ីចឹងខ្ញុំចង់សួរថា លោកបានឃើញអ្វីខ្លះនៅពេលគេប្រជុំហ្នឹង លោកមើលឃើញពីចម្ងាយ ឬក៏លោកស្តាប់ឮគេនិយាយទេ?

**ឆ៖** បាទ ខ្ញុំរត់សំបុត្រទៅដល់កន្លែងស្រុកហ្នឹង គេនិយាយពីរឿងផ្សឹកព្រះសង្ឃក៏ខ្ញុំអត់សួរដេញដោលដែរ។ ប៉ុន្តែក្នុងថ្ងៃហ្នឹងគេផ្សឹកព្រះសង្ឃ។

**ស៖** ដូច្នេះលោកបានស្តាប់ឮថា កូនស្រីរបស់តាម៉ុក ឈ្មោះ ខុម ជាអ្នករៀបចំ និងជាអ្នកដឹកនាំកិច្ចប្រជុំហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

[១៤:០៨:៣៤]

**ស៖** តើលោកអាចឆ្លើយបញ្ជាក់បានទេ ព្រោះថាលោក១ជានីរសារនៅសម័យនោះ។ អ៊ីចឹង តើលោកយកសំបុត្រពីក្រាំងតាចាន់ ទៅស្រុកត្រាំកក់ ឬក៏នៅពេលហ្នឹង គឺថាលោកនៅតែស្រុកត្រាំកក់ទេ?

**ឆ៖** បាទ មន្ទីរក្រាំងតាចាន់ ស្ថិតនៅក្នុងឃុំគុស បាទ ហើយខ្ញុំបញ្ជូនលិខិតហ្នឹងមកកន្លែងមន្ទីរស្រុកនៅអង្គរកា។

**ស៖** នៅពេលដែលលោកស្តាប់ឮគេនិយាយអំពីការប្រជុំដែលគេផ្សឹកព្រះសង្ឃ លោកបានឆ្លើយបញ្ជាក់ថា ពេលនោះគឺលោកនៅជានីរសាររបស់ស្រុកត្រាំកក់ គឺលោកមិនទាន់ផ្លាស់ទៅក្រាំងតាចាន់ទេ។ មានន័យថាអ៊ីចឹងទេ គឺថានៅពេលប្រជុំហ្នឹង គឺថាលោកនៅជានីរសារស្រុកនៅឡើយទេ មិនទាន់ទៅនៅក្រាំងតាចាន់ទេ?

**ឆ៖** បាទ ខ្ញុំអត់ដែរបាន។ ចម្លើយនេះ ខ្ញុំសូមកាត់ប្រសាសន៍បន្តិច ពីព្រោះចម្លើយនេះ ដូចខ្ញុំ

អត់បាននិយាយរឿងហ្នឹង ពីព្រោះខ្ញុំអត់ដែលនៅស្រុក អត់ដែលនៅនីរសារស្រុកទេ នៅនីរសារក្រាំងតាចាន់។

**សៈ** បាទសូមអរគុណ។ ដូច្នេះនៅពេលដែលលោកយកសំបុត្រទៅហ្នឹងលោកស្ដាប់ឮគេនិយាយអំពីការប្រជុំនៅវត្តអង្គរកា។ តើពេលលោកចាប់ផ្ដើមធ្វើការដំបូងនៅក្រាំងតាចាន់មែនទេពេលនោះ?

**ឆៈ** បាទ។

**សៈ** លោកបានឆ្លើយថា កិច្ចប្រជុំហ្នឹងនៅចុងឆ្នាំ៧៥។ អ៊ីចឹងលោកយល់ស្របទេថា លោកធ្វើការនៅក្រាំងតាចាន់ហ្នឹង គឺចាប់តាំងពីចុងឆ្នាំ១៩៧៥ មក?

**ឆៈ** បាទ។

**សៈ** ក្រោយពី យាយខុម និង តាជឹម ទៅតើអ្នកណាជាប្រធានស្រុកត្រាំកក់នោះ?

**ឆៈ** តាសាន និង យាយហឿន។

[១៤:១១:៤៦]

**សៈ** ចុះមុន តាសាន មានអ្នកណាផ្សេងទៀតដែលមានតួនាទីជាប្រធានស្រុកហ្នឹងក្នុងរយៈពេលមួយខ្លីទេ ឬក៏លោកមិនដឹងទេ?

**ឆៈ** បាទ អត់ដឹងទេបាទ។

**សៈ** តើលោកធ្លាប់ឮឈ្មោះ តាគៀវ ទេ ហើយធ្លាប់យកសំបុត្រទៅឲ្យគាត់ទេ? តាគិត ឬ តាចាយ? លោកធ្លាប់ទេ ធ្លាប់ឮឈ្មោះទាំងហ្នឹងទេ? ហើយធ្លាប់យកសំបុត្រទៅឲ្យពួកគាត់ទេ តាគៀវ តាចាយ?

**ឆៈ** ឈ្មោះ តាគៀវ ខ្ញុំអត់ដែលស្គាល់ទេ បើតាគិត និងតាចាយ ខ្ញុំដែលស្គាល់ ប៉ុន្តែអត់ដែលយកលិខិតទៅឲ្យទេ។

**សៈ** តើ តាជឹម និង តាគិត ហ្នឹងមានទំនាក់ទំនងសាច់ឈាមអីជាបងប្អូននិងគ្នាទេ?

**ឆៈ** បាទ គ្រាន់តែដឹងថា តាជឹម ហើយតាគិត បងប្អូនបង្កើត។

[១៤:១៣:២៤]

**សៈ** លោកនិយាយអំពី តាសាន និង យាយហឿន។ ខ្ញុំនិងត្រឡប់មកនិយាយអំពី យាយហឿន នៅពេលក្រោយ។ ឥឡូវខ្ញុំនិយាយអំពី តាសាន សិន។ ពេលណាដែរដែល តាសាន ឡើងជាគណៈស្រុកហ្នឹង?

**ឆៈ** បាទ ខ្ញុំមិនដឹងច្បាស់ដែរ ប៉ុន្តែខ្ញុំជួបហ្នឹង ឆ្នាំ៧៧ទៅហើយ។

**សៈ** អ៊ីចឹងនៅពេលដែលលោកជួបគាត់នៅឆ្នាំ១៩៧៧ ហ្នឹង គាត់ជាគណៈស្រុកហើយ ឬក៏គាត់មានតួនាទីអ្វីផ្សេងនៅក្នុងឃុំស្រុកហ្នឹង?

**ឆៈ** បាទ ខ្ញុំជួបហ្នឹងគាត់ធ្វើចៅហ្វាយស្រុកត្រាំកក់ហ្នឹងតែម្តង។

**សៈ** តើលោកដឹងទេ ថាពីមុននោះ គាត់ធ្លាប់ជាចៅហ្វាយឃុំ? ហើយលោកដឹងទេ ថាតើគាត់មកពីឃុំណាដែរ?

**ឆៈ** បាទ ខ្ញុំអត់ស្គាល់។

**សៈ** លោកស្គាល់គាត់ ឈ្មោះតែ តាសាន ទេ ឬក៏លោកស្គាល់ឈ្មោះពេញរបស់គាត់ដែរ?

**ឆៈ** បាទខ្ញុំស្គាល់តើ តាសាន។ ឈ្មោះគាត់មួយទៀត ខ្ញុំអត់ស្គាល់។

**សៈ** តើលោកដឹងថា តាសាន ហើយនិង តាម៉ុក ហ្នឹងមានទំនាក់ទំនងសាច់ឈាមនឹងគ្នាទេ?

**ឆៈ** បាទ ខ្ញុំអត់ដឹង។

**សៈ** នៅពេលដែល តាសាន ក្លាយជាគណៈស្រុកហ្នឹង មន្ទីររបស់គាត់នៅកន្លែងណាដែរ? ហើយគាត់រស់នៅទីណាដែរ?

**ឆៈ** ភាគច្រើននៅឃុំលាយបូរ។

**សៈ** ចុះមន្ទីររបស់គាត់នោះនៅអង្គរកាដដែល ឬក៏នៅកន្លែងណាផ្សេង?

**ឆៈ** មន្ទីររបស់គាត់នៅអង្គរកាដដែល។

[១៤:១៥:៥៧]

**សៈ** ពាក់ព័ន្ធនឹងយាយហឿន នៅក្នុងកំណត់ហេតុរបស់លោកគឺលេខ E319.1.13។ ខ្ញុំនឹងដកស្រង់ចម្លើយរបស់លោកគឺ "ចម្លើយលេខ៨២៖ ខ្ញុំស្គាល់ ហឿន គឺជាស្ត្រីម្នាក់ គាត់ជាអនុប្រធានស្រុកត្រាំកក់ នៅឆ្នាំ១៩៧៨ គាត់ជាអនុរបស់ សាន។ ខ្ញុំមិនធ្លាប់យកសំបុត្រទៅឲ្យឈ្មោះ ហឿន ទេ"។ នៅក្នុងចម្លើយ៨៣ លោកឆ្លើយថា "អ្នកណាក៏ស្គាល់ឈ្មោះ យាយហឿន ដែរនៅស្រុកត្រាំកក់"។ ហើយនៅចម្លើយទី៨៦ លោកនិយាយថា "ហឿន និង តាអាន់ នៅក្រាំងតាចាន់ហ្នឹងជាបងប្អូនជីដូនមួយនឹងគ្នា"។ ចម្លើយ -- សំណួរទី៨៧៖ "តើហឿនអាចរស់នៅ ឬក៏ធ្វើការនៅស្រុកត្រាំកក់ដែរឬទេ នៅឆ្នាំ១៩៧៧? ពេលនោះលោកឆ្លើយនូវចម្លើយទី៨៧ថា៖ "បាទ ត្រឹមត្រូវ ព្រោះពេលនោះ យាយហឿន ជាមេឃុំជាងទង"។ "សំណួរ៖ តើឈ្មោះហឿនធ្វើមេឃុំជាងទងនៅឆ្នាំណា? ចម្លើយ៨៨៖ ប្រហែលជានៅឆ្នាំ១៩៧៧ ឬ១៩៧៨"។ សំណួរ១០៤ចុះមកក្រោយបន្តិចមក "តើហឿនៗធ្វើជាអនុស្រុករបស់ តាសាន រហូតដល់

ពេលដែលខ្មែរក្រហម -- របបខ្មែរក្រហមចប់នៅឆ្នាំ១៩៧៩ ឬក៏យ៉ាងណា?" បាទ លោកឆ្លើយថា៖ "បាទ រហូតដល់ពេលដែលខ្មែរក្រហមដួលរំលំ"។ សូមបញ្ចប់ការដកស្រង់។ នៅពេលដែល តាសាន ជាគណៈស្រុកហ្នឹង លោកធ្លាប់ឃើញតាសាននិងយាយបឿននៅជាមួយគ្នាទេនៅមន្ទីរស្រុកត្រាំកក់ហ្នឹង?

[១៤:១៨:២៣]

**ឆ៖** បាទ ខ្ញុំមិនដែលបានដឹងដែរពីរឿងកិច្ចការអស់ទាំងហ្នឹងបាទ។

**ស៖** ខ្ញុំទទួលចម្លើយលោកបានតែមួយផ្នែកទេ។ តើយាយខុមនៅឆ្នាំ១៩៧៥ តាជឹម, តាគិត តាចាយ, តាសាន នៅស្រុក១០៥ មកៗពិនិត្យមើលមន្ទីរក្រាំងតាចាន់ទេ បើតាមលោក អ្វីដែលលោកបានសង្កេតឃើញនៅពេលដែលលោកនៅក្រាំងតាចាន់នោះ ពួកគាត់ធ្លាប់មកទេ?

**ឆ៖** បាទ ចៅហ្វាយស្រុកកាលនោះ គេមិនដែលទៅពិនិត្យធ្វើពិនិត្យទេ គេសង្ឃឹមលើប្រធាននៅហ្នឹងមួយបាទ។

**ស៖** តើមានអ្នកណាផ្សេងទៀត ដែលមកៗពីស្រុក១០៥ មកមើលក្រាំងតាចាន់ ឬក៏មកធ្វើការ ឬក៏មកពិនិត្យការងារនៅមន្ទីរហ្នឹងទេ -- មន្ទីរក្រាំងតាចាន់ហ្នឹងទេ? ខ្ញុំនិយាយអំពីកម្មាភិបាលស្រុក១០៥ តើមានអ្នកណាផ្សេងទៀតដែលធ្លាប់មកមន្ទីរក្រាំងតាចាន់ហ្នឹង?

**ឆ៖** កាលណោះ មានតាភី មួយទេ បាទ តាភី បាក់ជើងមួយ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយពី តាភី នៅពេលក្រោយ។ អ៊ីចឹងនៅពេលនេះខ្ញុំចង់ដឹងថា មានអ្នកផ្សេងទៀតទេដូចជា តាឌុច, តាកន, តារស់, មានធ្លាប់មកទេក្រាំងតាចាន់ហ្នឹង?

**ឆ៖** ខ្ញុំស្គាល់តែតាឌុច។ បើតារស់ ហើយតាកន ខ្ញុំអត់បានស្គាល់ទេ។

[១៤:២០:៥៤]

**ស៖** ខ្ញុំនឹងអានចម្លើយរបស់លោក។ លោកបាននិយាយថា បន្ទាប់ពីចេញពីទីរួមខេត្តតាកែវគឺ ក្នុងកំណត់ហេតុ D40/23 គឺចម្លើយទី១តែម្តង គឺភាសាបារាំង គឺ 00490906, ជាភាសាអង់គ្លេស 00223208, ជាភាសាខ្មែរ 00165352។ លោកឆ្លើយថា៖ "ចាប់ពីថ្ងៃ ១៧ មេសា ៧៥ មកខ្ញុំដំបូងនៅជាទ័ពស្រុក បន្ទាប់មកគេផ្លាស់ទៅឈរជើងនៅភ្នំដំរីរមៀល ក្នុងភូមិត្រពាំងលាន ឃុំគុស ស្រុកត្រាំកក់។ បន្ទាប់មកគេឲ្យមកឈរជើងនៅភូមិត្រពាំងពោធិ៍ ឃុំជាងទង ហើយបន្ទាប់មកទៀត គេឲ្យខ្ញុំទៅនៅមន្ទីរក្រាំងតាចាន់"។ សូមបញ្ចប់ការដកស្រង់។ ហើយនៅក្នុងកំណត់ហេតុមួយទៀតរបស់លោកគឺ E319.1.33 នៅក្នុងចម្លើយ-សំណួរ២៧ គេសួរលោកថា "តើលោកឈរនៅភ្នំដំរីរមៀលហ្នឹង គេឲ្យ

លោកធ្វើអ្វីខ្លះ?" លោកបានឆ្លើយថា៖ "គឺយាមចាំចាប់ខ្មាំងនៅតាមជើងភ្នំ ប៉ុន្តែអត់មានខ្មាំងនោះទេ"។ សូមបញ្ចប់ការដកស្រង់ចម្លើយរបស់លោក។ នៅភ្នំដំរីរមៀល គឺនៅក្នុងឃុំត្រពាំង -- នៅក្នុងភូមិត្រពាំងលាន ឃុំគុស ស្រុកត្រាំកក់ ឆ្នាំ១៩៧៥ នោះលោកនិយាយថាតួនាទីរបស់លោកនោះគឺយាមចាំចាប់ខ្មាំង។ តើលោកនិយាយខ្មាំងហ្នឹង ជាខ្មាំងអ្វីដែរនៅពេលហ្នឹង?

**ឆ៖** ខ្មាំងដែលគេបង្កឡើង ឲ្យតែរត់ចេញពីសហករណ៍ ឬមួយក៏ចេញពីមូលដ្ឋានទៅនៅព្រៃភ្នំហ្នឹងគេចោទ ថាខ្មាំងតែម្តង។

[១៤:២០:៣៥]

**ស៖** តើមានមនុស្សដែលចង់រត់ចេញពីសហករណ៍ហ្នឹងច្រើនទេ?

**ឆ៖** កាលពីសម័យហ្នឹងអត់មានដែរ បាទ។

**ស៖** តើលោកគេមានប្រាប់លោកទេថាត្រូវធ្វើយ៉ាងម៉េចនៅពេលដែលចាប់ខ្មាំងបាននោះ?

**ឆ៖** កាលណោះគេគ្រាន់តែប្រាប់ថា "ធ្វើម៉េចចាប់ឲ្យបានកុំធ្វើអ្វីគេឲ្យសោះ" គ្រាន់តែថាប៉ុណ្ណឹងទេ។

**ស៖** នៅពេលនោះតើលោកមានធ្លាប់ឮឈ្មោះ ព្រំ សាន់ទេ? ប្រហែលជាអាចគេចាប់ខ្លួនគាត់។

**ឆ៖** បាទពិតមែន។

**ស៖** អ៊ីចឹង ព្រំ សាន់ ហ្នឹងជាអ្នកណាដែរ?

**ឆ៖** ខ្ញុំ មកទើបដឹងច្បាស់បច្ចុប្បន្នឥឡូវដែរ ព្រំ សាន់ហ្នឹងគាត់ កាលនោះគាត់ថាក្បត់បដិវត្តន៍ ហើយដល់គាត់ជាប់ធ្វើមេឃុំនៅស្រុកត្រាំកក់បច្ចុប្បន្ននេះ ក៏ខ្ញុំឮគេនិយាយនៅសាលាស្រុកថា គាត់ក្បត់នឹងគេ ហើយដល់គេរកចាប់គាត់ៗរត់ឡើងព្រៃបាទ។

**ស៖** នៅពេលដែលលោកនៅភ្នំដំរីរមៀល ហើយបន្ទាប់មកទៀតគេចាប់ឲ្យលោកទៅភូមិត្រពាំងពោធិ៍នោះ។ តើអ្នកយាមនៅមន្ទីរក្រាំងតាចាន់ហ្នឹងឈ្មោះ សេង ហើយនិង ស៊ីម ហ្នឹង ពេលនោះគាត់នៅជាមួយនឹងក្រុមរបស់លោកនឹងទេ?

**ឆ៖** បាទ។

**ស៖** នៅភូមិត្រពាំងពោធិ៍ ឃុំជាងទង លោកធ្វើអ្វីដែរ? ហើយនៅទីនុំងលោកនៅយូរទេ? គេចាត់ឲ្យលោកធ្វើអីដែរនៅទីនោះ?

[១៤:២៦:៣២]

**ធ៖** កាលនោះ គេប្រាប់ខ្ញុំពីនោះមកថាឲ្យមកចាំចាប់ សេ.អ៊ី.អា នៅទីកន្លែងនោះភូមិត្រពាំង-ពោធិ៍ ឃុំជាងទងហ្នឹង តែអត់មានឃើញអីសោះ មកឈរជើងប្រហែលជាជិតមួយខែបាទ។

**សៈ** ខ្ញុំចង់អានសម្រង់កំណត់ហេតុរបស់ ស៊ឹម ជាអតីតអ្នកយាមនៅមន្ទីរក្រាំងតាចាន់។ តើ ស៊ឹម ហ្នឹងមកពីភូមិតែមួយជាមួយលោកមែនទេ ភូមិជ្រៃ ឃុំលាយបូរ?

**ធ៖** បាទ។

**សៈ** កំណត់ហេតុស្តាប់ចម្លើយរបស់គាត់គឺលេខ D40/20 ជាភាសាខ្មែរគឺលេខ 00165329, ជាភាសាអង់គ្លេស 00433569, ជាភាសាបារាំង 00524317។ ស៊ឹម បានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "បន្ទាប់ពីភ្នំពេញដួលរលំនៅឆ្នាំ១៩៧៥ ខ្ញុំធ្វើការជាកងទ័ពនៅតាកែវ។ បន្ទាប់មកទៀត គេបញ្ជូនខ្ញុំទៅតំបន់ដំរីរមៀល"។ បន្ទាប់មកទៀតគាត់ឆ្លើយថា៖ "នៅឆ្នាំ១៩៧៦ នៅរដូវច្រូតកាត់ គាត់ គេត្រូវបញ្ជូនជាថ្មីម្តងទៀតទៅក្រាំងតាចាន់"។ គាត់និយាយថា៖ "នៅពេលដែលខ្ញុំទៅដល់ក្រាំងតាចាន់ គេឲ្យខ្ញុំទៅភូមិត្រពាំងពោធិ៍ ៣ថ្ងៃ ៣យប់ ដើម្បីចាប់អនុសេនីយ៍ឯកកងទ័ពលន់ នល់ ដែលនឹងមានទំនាក់ទំនងនៅទីនោះ។ នៅពេលនោះខ្ញុំមិនអាចចាប់គាត់បានទេ"។ បញ្ចប់ការដកស្រង់។ តើលោកនៅចាំទេអំពីភារកិច្ចដែលលោកត្រូវធ្វើនៅភូមិត្រពាំងពោធិ៍នោះ?

**ធ៖** បាទ នៅចាំ។

[១៤:២៩:២០]

**សៈ** ស៊ឹម បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា គាត់ត្រូវចាកចេញពីក្រាំងតាចាន់ទៅភូមិត្រពាំងពោធិ៍ ដើម្បីចាប់ខ្លួនទាហានលន់នល់ម្នាក់ ហើយគាត់អត់អាចចាប់បានទេ។ តើលោកមានចាំទេថា អ្នកយាមនៅក្រាំងតាចាន់ត្រូវបានគេបញ្ជូនជាញឹកញាប់ពីក្រោមន្ទីរក្រាំងតាចាន់ ដើម្បីឲ្យទៅចាប់មនុស្សនោះ? ឬក៏ឲ្យមានការ ឬក៏សម្រាប់ឲ្យទៅបញ្ជូនអ្នកទោសចេញទៅណាមួយនោះ?

**ធ៖** ខ្ញុំអត់ដឹងដែរ នៅត្រង់ចន្លោះហ្នឹង ពីព្រោះខ្ញុំនៅក្មេង គេមិនសូវទាក់ទងបាទ។

**សៈ** ក៏ប៉ុន្តែលោក១គឺបានទៅភូមិត្រពាំងពោធិ៍ តើអ្នកណាជាអ្នកប្រាប់លោកឲ្យទៅភូមិត្រពាំងពោធិ៍នោះ?

**ធ៖** ឈ្មោះតា -- ឈ្មោះ តាអាន់។

**សៈ** នៅក្នុងកំណត់ហេតុដដែល គឺនៅទំព័រដដែល "ស៊ឹម បាននិយាយថា បន្ទាប់ពីមកភូមិត្រពាំងពោធិ៍វិញ គេឲ្យខ្ញុំយាមអ្នកទោស បន្ទាប់មកទៀត គេបញ្ជាឲ្យខ្ញុំទៅផ្ទះរបស់យាយឃឹម ដើម្បី

ទទួលមនុស្សដែលគេនាំមក”។ សូមបញ្ចប់ការដកស្រង់។ ចុងក្រោយមក គាត់ច្រឡំ គាត់មិនបានទៅផ្ទះ យាយឃីម ទេ។ អ៊ីចឹង ខ្ញុំចង់ដឹងថានៅពេលដែលគាត់ឆ្លើយថា គេបញ្ជាឲ្យគាត់ទៅផ្ទះ យាយឃីម នេះ លោកមានទៅជាមួយគាត់ទេ?

**ផ៖** បាទ ខ្ញុំអត់ទេ។

[១៤:៣១:៣១]

**ស៖** លោកបានឆ្លើយថាគេបញ្ជូនលោកទៅមន្ទីរក្រាំងតាចាន់នៅឆ្នាំ១៩៧៥។ តើលោកដឹងអ្វីខ្លះនៅមន្ទីរក្រាំងតាចាន់នេះ មុនពេលដែលគេឲ្យលោកទៅ? មុនទៅហ្នឹងលោកធ្លាប់ឮគេនិយាយថា មន្ទីរហ្នឹងសម្រាប់ធ្វើអីទេ មន្ទីរក្រាំងតាចាន់ហ្នឹង?

**ផ៖** កាលមុនគេបញ្ជូនខ្ញុំទៅ គេថាទៅមន្ទីរសន្តិសុខបាទ។ គេគ្រាន់តែប្រាប់តែប៉ុណ្ណឹងទេ។

**ស៖** លោកដឹងទេថា មន្ទីរសន្តិសុខហ្នឹង គេប្រើសម្រាប់ធ្វើអ្វីដែរនៅក្នុងរបបខ្មែរក្រហមហ្នឹង? លោកដឹងថាក្នុងហ្នឹងគេឃុំអ្នកទោស គេសួរចម្លើយអ្នកទោស ឬក៏គេសម្លាប់អ្នកទោសទេ?

**ផ៖** ជាដំបូងខ្ញុំក៏អត់បានដឹងដែរ ទាល់តែគេបញ្ជូនដល់រយៈពេលកន្លះខែ គេចែកដីឲ្យដើរបាទ។

**ស៖** លោកបានឆ្លើយថា គេបញ្ជូនលោកទៅក្រាំងតាចាន់ ហើយលោកបាននិយាយអំពីឈ្មោះមួយ គឺប្រធានកងហាស្រុក ឈ្មោះ ពីន ដែលគេ -- ដែលគាត់ហ្នឹងហើយ ជាអ្នកប្រាប់លោកថាឲ្យលោកទៅក្រាំងតាចាន់ហ្នឹង។ គឺនៅក្នុងឯកសារលេខ D40/23 លោកឆ្លើយថាឈ្មោះគាត់ហ្នឹងជាអ្នកបញ្ជូន -- អ្នកឲ្យលោកទៅ។ អ៊ីចឹងប្រធានកងហាឈ្មោះ ភីន។ លោកដឹងទេថា នៅពេលដែលគាត់ប្រាប់លោកឲ្យទៅហ្នឹង លោកដឹងថាអ្នកណាទេជាអ្នកសម្រេចថាបញ្ជូនលោកទៅមន្ទីរក្រាំងតាចាន់នោះ?

**ផ៖** កាលនោះ ខ្ញុំអត់ដឹងដែរ បាទ។

[១៤:៣៣:២៩]

**ស៖** ខ្ញុំសូមអានសម្រង់កំណត់ហេតុរបស់លោក គឺលេខ D40/23 នៅទំព័រជាភាសាខ្មែរ 00165353 រហូតទៅដល់54, ជាភាសាបារាំងគឺ 00490908, ជាភាសាអង់គ្លេស 00223201។ ខ្ញុំប្រហែលជាច្រឡំ ប្រហែលជាអាច 10 ទេ។ លោកឆ្លើយថា៖ “នៅមន្ទីរក្រាំងតាចាន់ តើមានមនុស្សប៉ុន្មាននាក់ដែលធ្វើដូចលោកនោះ?” លោកឆ្លើយថា “មានប្រាំមួយនាក់ គេឲ្យយាម”។ “តើអ្នកប្រាំមួយនាក់ហ្នឹងឈ្មោះអ្វីខ្លះ?” លោកឆ្លើយថា “មានឈ្មោះ ឌុច មានឈ្មោះ ស៊ីម, សាំង, ទូច, អ៊ួក និងខ្ញុំផ្ទាល់”។ ដូច្នេះ យើងបាននិយាយពីលោក ពីស៊ីម ពីសាំង រួចហើយ។ លោកឆ្លើយថាខ្សែជីវិតរបស់

ពួកគាត់ដូចលោកអ៊ីចឹង គឺថាដំបូងឡើង គឺទៅស្រុក បន្ទាប់មកទៅភ្នំដំរីរមៀល ភូមិត្រពាំងពោធិ៍។ តើឌុច – ឌុចតូច ហើយនិង អ៊្លកហ្នឹង ក៏មានដូចលោកដែរមែនទេ? មានប្រវត្តិដូចលោកដែរ គឺថាបាន ឆ្លងកាត់ខ្សែជីវិតដូចលោក ហើយមកដល់ក្រាំងតាចាន់ហ្នឹងក៏ក្នុងពេលតែមួយជាមួយនឹងលោកដែរ។ តើមែនទេ?

**ឆ៖** បាទ។

**ស៖** តើភារកិច្ចទី១របស់លោក លោកត្រូវធ្វើអ្វីក្នុងឋានៈលោកជាអ្នកយាមនៅមន្ទីរសន្តិសុខ ក្រាំងតាចាន់នោះ?

**ឆ៖** បាទខ្ញុំគ្រាន់តែយាមនៅទីនោះ យាមទាំងថ្ងៃទាំងយប់ ហើយម្យ៉ាងទៀត ថ្ងៃ គេឱ្យរត់ សំបុត្របាទ ប៉ុណ្ណឹង។

[១៤:៣៦:០៧]

**ស៖** នៅពេលដែលគេចាត់លោកឱ្យទៅនៅក្រាំងតាចាន់ តើមានអ្នកទោសក្មេងម្នាក់ឈ្មោះ សែន ដែលគាត់ធ្វើការនៅមន្ទីរហ្នឹង គាត់ឃ្វាលគោ ដាំបន្លែ ឬក៏ឡើងត្នោត ឬក៏ជីករណ្ដៅ? លោកមានស្គាល់ទេ ក្មេងម្នាក់ឈ្មោះ សែន នៅពេលដែលលោកទៅដល់នោះ?

**ឆ៖** បាទ ទៅដល់នោះបានខ្ញុំស្គាល់។ បាទ ស្គាល់។

**ស៖** ខ្ញុំនឹងដកស្រង់នូវចម្លើយរបស់លោក។ លោកបាននិយាយពីឈ្មោះរបស់គាត់នៅក្នុង ឯកសារលេខ D40/23 គឺជាទំព័រជាភាសាខ្មែរ 00165357, ជាភាសាបារាំង 00490912, ជាភាសា អង់គ្លេស 00223212។ “សំណួរ៖ ក្នុងចំណោមអ្នកដែលគេនាំអ្នកទោសនាំមកមន្ទីរហ្នឹង តើមានអ្នក ណាត្រូវបានដោះលែងទេ?” លោកឆ្លើយថា៖ “មានអ្នកទោសស្រីជាមួយនឹងកូនតែប៉ុណ្ណោះដែលគេដោះ លែង ជាពិសេសគ្រួសារ យាយញ៉ៅ។ ចំពោះអ្នកទោសប្រុសនោះ ភាគច្រើនគឺស្លាប់ដោយសារជំងឺ និង ការសម្លាប់។ អ្នកទោសតិចណាស់ដែលអាចមានរស់រានមានជីវិតនោះ គឺមានក្នុងនោះមានឈ្មោះ សែន ដែលរស់នៅជិតវត្តអង្គរលាយ”។ សូមបញ្ចប់ការដកស្រង់។ ក្នុងឯកសារនេះ គឺលោកបាននិយាយអំពី គ្រួសារ យាយញ៉ៅ។ នៅក្នុងចម្លើយលេខ៩០ ទៅដល់៩២ នៃកំណត់ហេតុ E319.1.33 គឺ ៩០ ទៅដល់ ៩២ លោកបាននិយាយអំពីសមាជិកគ្រួសារ យាយញ៉ៅ ដែលជាអ្នកទោស ក៏ប៉ុន្តែបានរស់រានមានជីវិតពី មន្ទីរក្រាំងតាចាន់។ នៅក្នុងកំណត់ហេតុមួយទៀត ដែលខ្ញុំទើបតែដកស្រង់អម្បាញ់មិញនេះក៏លោកបាន និយាយផងដែរថា អ្នកទោសស្លាប់ដោយសារការវាយដំក្នុងពេលសួរចម្លើយ។ ហើយលោកបាននិយាយ

អំពីប្ដី យាយញ៉ូ ហើយនិងប្ដីរបស់ឈ្មោះ រ៉ាត់ ដែលជាកូនស្រីរបស់ យាយញ៉ូ។ លោកអាចប្រាប់បានទេថានៅពេលដែលលោកទៅដល់មន្ទីរក្រាំងតាចាន់ តើសមាជិកគ្រួសាររបស់ យាយញ៉ូ នៅទីនោះរួចទៅហើយ ឬក៏ពួកគាត់មកនៅក្រោយពេលដែលលោកទៅដល់ហើយទេ?

[១៤:៣៩:១២]

**ឆ៖** បាទ គ្រួសារលោក យាយញ៉ូ ហ្នឹង ខ្ញុំនៅទីនោះហើយបាទ។

**ស៖** លោកសាក្សីនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺលេខ E319.1.33 លោកឆ្លើយនូវចម្លើយទី៩០។ នៅពេលនោះគេសួរសំណួរលោកថា៖ “តើលោកដឹងអំពីការចាប់ខ្លួនប្រជាជននៅភូមិស្រែគ្រួដែរឬទេ?” លោកឆ្លើយនៅចម្លើយទី៩០ថា៖ “ដំបូងនៅឆ្នាំ១៩៧៧ គេចាប់ខ្លួនមនុស្សពីរគ្រួសាររួមទាំងប្រពន្ធ និងកូននៅក្នុងភូមិស្រែគ្រួនេះ។ ប៉ុន្តែក្រោយមកនៅឆ្នាំ១៩៧៨ គេបានដោះលែងប្រពន្ធ និងកូនឲ្យត្រឡប់មកភូមិស្រែគ្រួវិញ ហើយខ្ញុំជាអ្នកនាំប្រពន្ធនិងកូនរបស់ពួកគេមកវិញ”។ សំណួរ៖ តើលោកចាំឈ្មោះអ្នកទាំងនោះដែរឬទេ?” លោកឆ្លើយនៅចម្លើយទី៩១ថា៖ “គ្រួសារទី១ មានឈ្មោះ គុន ជាប្ដីរបស់ យាយញ៉ូ ហើយមានកូនឈ្មោះ ខា, រ៉ាត់ និងម្នាក់ទៀតខ្ញុំមិនចាំឈ្មោះនោះទេ។ គុន ដែលជាប្ដី យាយញ៉ូ នោះជាអ្នកជាប់គុកនៅក្រាំងតាចាន់។ គ្រួសារទី២ មានឈ្មោះ រ៉ាត់ (កូនរបស់ គុន និង យាយញ៉ូ) មានប្ដីឈ្មោះ បឿន ជាអ្នកជាប់ឃុំនៅគុកក្រាំងតាចាន់”។ ដូច្នេះលោកឆ្លើយថាពួកគាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ ក៏ប៉ុន្តែលោកឆ្លើយថាលោកនៅក្រាំងតាចាន់ហ្នឹងនៅឆ្នាំ១៩៧៥។ អ៊ីចឹងពាក់ព័ន្ធនឹងកាលបរិច្ឆេទទាំងនេះ ខ្ញុំអានទៅធ្វើឲ្យលោកនឹកឃើញឡើងវិញទេ? អ៊ីចឹងលោកឆ្លើយម្ដងទៀតទៅមើល ថាលោកនៅពេលទៅដល់ហ្នឹងលោកឃើញពួកគាត់នៅទីនោះហើយ ឬក៏គេចាប់ខ្លួនពួកគាត់មកនៅពេលដែលលោកទៅដល់ហើយទេ?

**ឆ៖** បាទ ខ្ញុំនៅមុនចាប់ខ្លួនគាត់បាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណ។ លោកប្រធានខ្ញុំមើលទៅ ឃើញថាម៉ោងដល់ពេលសម្រាកហើយ សូមលោកប្រធានសម្រេច។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ។ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ
ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ រួមទាំងមេធាវីប្រឹក្សាផង នៅពេលវេលាម៉ោង៣បី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០២:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមកែតម្រូវនូវពេលវេលាសម្រាប់សួរដេញដោលសាក្សីរូបនេះ គឺភាគីម្ខាងៗហ្នឹង គឺមេធាវី -- សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលា១ថ្ងៃក្នុងការសួរសាក្សីរូបនេះ។ អំមិញនេះ គឺយើងថា១ថ្ងៃ ហើយថែមមួយវគ្គសវនាការទៀត តែតាមពិតតែ១ថ្ងៃទេ។ សូមជម្រាប។

បាទ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី បាទឥឡូវនេះ ខ្ញុំចូលទៅនិយាយប្រធានបទមួយទៀត ដែលទាក់ទងនឹងរចនាសម្ព័ន្ធ ហើយនិងការរៀបចំបុគ្គលិកនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ នៅពេលដែលលោកទៅដល់ក្រាំងតាចាន់ហ្នឹងនៅចុងឆ្នាំ៧៥ នៅមន្ទីរក្រាំងតាចាន់ហ្នឹង តើលោកឈប់ទទួលបញ្ជាពីមេចាស់ មេកងហារបស់លោក គឺលោក ភីន ឬក៏ជាអតីតមេទាហាននៅក្នុងស្រុកហ្នឹងហើយ ឬក៏នៅតែបន្តទទួលបញ្ជា

ពីពួកគាត់ទៀត?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ អត់ទេ។

**ស៖** ពេលដែលលោកទៅដល់ក្រាំងតាចាន់ហើយ អ្នកណាជាអ្នកទទួលបញ្ជាទៅបុគ្គលិកទាំងអស់ ដែលធ្វើការនៅមន្ទីរនោះ? អ្នកណាជាអ្នកដែលធ្វើឲ្យគេគោរពវិន័យ ហើយអ្នកណាជាអ្នកដឹកនាំកិច្ចប្រជុំនៅមន្ទីរក្រាំងតាចាន់នោះ?

[១៥:០៤:៤០]

**ឆ៖** បាទ ឈ្មោះ អាន់ និង ពេញ។

**ស៖** តើតាអាន់ និងតាពេញ ហ្នឹងមានតួនាទីអ្វីដែរ?

**ឆ៖** គេបក្ខជន បាទ។

**ស៖** តើគាត់ណាជាអ្នកដឹកនាំមន្ទីរក្រាំងតាចាន់ហ្នឹង?

**ឆ៖** តាអាន់។

**ស៖** ហើយ តាពេញ ហ្នឹងគាត់ធ្វើអ្វីដែរ បើធៀបទៅហ្នឹង តាអាន់?

**ឆ៖** គាត់អនុប្រធាន។

**ស៖** ចំពោះលោកផ្ទាល់តើអ្នកណាបញ្ជាឲ្យលោករត់សំបុត្រនោះ? ជានីរសារនោះ?

**ឆ៖** បាទ តាអាន់។

**ស៖** នៅពេលដែលលោកទៅដល់នោះជាមួយអ្នកយាមប្រាំនាក់ទៀត ក្រៅពីតាអាន់ ហើយនិងតាចេងហ្នឹង តើអ្នកណាជាគណៈ អ្នកដឹកនាំនៅមន្ទីរក្រាំងតាចាន់ហ្នឹង?

**ឆ៖** បាទ អត់មានទេ មានតែពីរហ្នឹងផ្ទាល់តែម្តង។

**ស៖** បាទ លោកបាននិយាយអំពីឈ្មោះ ចេង នៅក្នុងចម្លើយស្តាប់ចម្លើយរបស់លោកគឺឯកសារ D40/23, ERN ជាភាសាខ្មែរគឺ 00165352, ជាភាសាបារាំង គឺ 00490907 ដល់ 08, អង់គ្លេស គឺ 00223209។ ហើយលោកឆ្លើយថា -- "សំណួរ៖ ថាតើអ្នកដឹកនាំមច្ឈមជាអ្នកណា? គឺឈ្មោះអាន់ គាត់ជាប្រធានមន្ទីរក្រាំងតាចាន់ ហើយខ្ញុំឈ្មោះ -- ខ្ញុំភ្លេចឈ្មោះ ត្រកូលគាត់ហើយ។ ទាក់ទងទៅនឹងការៗអនុវត្តផែនការ ក្រៅពី អាន់ ដែលជាប្រធាន តើមានអ្នកណាផ្សេងទៀត ដែរឬទេ? ចម្លើយ៖ ក្រៅពីអាន់ មានឈ្មោះ ពេញ ហើយនិងចេង ខ្ញុំមិនឈ្មោះត្រកូលរបស់ពួកគាត់ទេ"។ តើឈ្មោះ ចេង នេះ

លោកដឹងថាគាត់មានមុខតំណែងអ្វីជាក់លាក់ទេ នៅមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹង?

**ឆ៖** បាទ អត់ទេ។ ខ្ញុំអត់ដែលស្គាល់គាត់ មុខរបរជំនាញខាងអ្វី ខ្ញុំក៏អត់ដឹងដែរ។ គ្រាន់តែគាត់ដឹងថា គាត់ផ្នែកទាំងប្រាំមួយនាក់ គាត់ជាបក្ខជន។

[១៥:០៨:៤៥]

**ស៖** តើលោកមានចាំឈ្មោះសមាជិកទាំងប្រាំមួយនាក់ហ្នឹងដែរឬទេ ក្រៅពីនាក់ទាំងប៉ុន្មាននាក់ដែលខ្ញុំបាននិយាយអំមិញនេះ គឺតាអាន់, ពេញ, ចេង ហ្នឹង មានឈ្មោះណាផ្សេងទៀតទេ ជាបក្ខជនដែរ?

**ឆ៖** ឈ្មោះ អាន់ ហ្នឹង, ពេញ, ចេង, ឈៀង, ឈឿន មួយទៀតឈ្មោះ ដែល ឈៀង មានពីរ បាទ ឈៀង មានពីរ។ ហើយឌុច ប្រធានយុវជនស្រុក។

**ស៖** នៅក្នុងចម្លើយរបស់លោកដដែលហ្នឹង គឺថាលោកក៏បាននិយាយពីឈ្មោះ មឿន។ តើលោកស្គាល់ឈ្មោះ មឿន ហ្នឹងទេ ក្នុងបក្ខជននេះ ចំណោមបក្ខជនទាំងអស់នោះ?

**ឆ៖** បាទស្គាល់ ខ្ញុំបាទភ្លេចអំមិញបាទ។

**ស៖** តើហេតុអ្វីបានលោកដឹងថា មនុស្សទាំងប្រាំមួយ ឬប្រាំពីរនាក់នេះជាបក្ខជន ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** បាទ គេប្រជុំពីរផ្នែក។

**ស៖** ខ្ញុំអម្បាញ់មិញ ខ្ញុំសួរលោកថា តើមនុស្សទាំងប្រាំមួយនាក់នោះបានប្រាប់ថា គាត់ជាបក្ខ-ជន ឬក៏សមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ហើយថាហេតុអ្វីបានលោកដឹងថាគាត់ជាបក្ខជន?

**ឆ៖** គឺសំដៅទៅលើខ្ញុំពិនិត្យទៅមើលឃើញថា គេប្រជុំពីរផ្នែកបាទ។ ប្រជុំផ្នែកការពារដោយឡែក ប្រជុំបក្ខជនដោយឡែក។

[១៥:១១:២៨]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងគឺថាមានបក្ខជនប្រាំមួយរូប ដែលជាមនុស្ស -- ជាអ្នកការពារសន្តិសុខនៅទីនោះ។ អ៊ីចឹងជាការសមស្របដែរឬទេក្នុងការនិយាយថា អង្គភាពរបស់លោកទាំងប្រាំមួយនាក់ហ្នឹងជាស្ថិតនៅក្រោមបង្គាប់នៅអង្គភាពដែលមានមនុស្សទាំងប្រាំមួយនាក់ហ្នឹង ជាបក្ខជនហ្នឹង?

**ឆ៖** បាទ។

**ស៖** អ៊ីចឹងក្នុងឋានៈជាកូនចៅគេ តើត្រូវគោរពបញ្ជាដែលបក្ខជនហ្នឹងដាក់ចេញទេ ហើយនិងគណៈកម្មការ នឹងចេញពីគណៈមន្ទីរក្រាំងតាចាន់ហ្នឹង ឬក៏លោកអ្នកទាំងអស់គ្នានេះ អ្នកទាំងប្រាំមួយ

នាក់ហ្នឹងមានសិទ្ធិមិនធ្វើតាមទេ?

**ឆ៖** បាទ ទាំងប្រាំមួយនាក់ផ្នែកការពារខាងក្រៅបាទ។

**ស៖** សំណួរខ្ញុំអម្បាញ់មិញនេះ គឺខ្ញុំចង់ដឹងថា ក្នុងឋានៈជាកូនចៅនៅ -- ដែលនៅក្នុងក្រុមដែលជាសមាជិកបក្សហ្នឹង យើងត្រូវគោរពបញ្ជាដែលគេដាក់ឲ្យ ដើម្បីបំពេញការងាររបស់ខ្លួន។ ឧទាហរណ៍គេប្រើឲ្យធ្វើអ្វីមួយអ៊ីចឹង ដូចជាលោកផ្ទាល់គឺឲ្យធ្វើជានីរសារអីជាដើមនេះ ត្រូវគោរពបញ្ជាគេទេ?

**ឆ៖** បាទ ត្រូវតែគោរពគេ ពីព្រោះគេដាក់បទបញ្ជាមកបាទ។

**ស៖** តើលោកមានបានដឹងថា អាចមានរឿងអីកើតឡើងទេ បើសិនជាអត់បានគោរពវិន័យហើយនិងបញ្ជារបស់គណៈគ្រប់គ្រងមន្ទីរសន្តិសុខក្រាំងតាចាន់នោះ មានរឿងអីកើតឡើងដែរ ប្រសិនបើអត់គោរពវិញ?

[១៥:១៣:៥៤]

**ឆ៖** បើអត់គោរពវិញ គេយកយើងចូលគុកបាទ។

**ស៖** តើមានករណីអ្នកយាមហ្នឹងមិនគោរពវិន័យ ហើយក្រោយមកក៏ធ្លាក់ខ្លួនទៅជាអ្នកទោសនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹងដែរឬទេ?

**ឆ៖** បាទ មាន។

**ស៖** តើលោកអាចប្រាប់ឈ្មោះបុគ្គលហ្នឹងដែរឬទេ ដែលត្រូវបានគេដាក់ឲ្យក្លាយជាអ្នកទោសវិញ ដោយមូលហេតុមិនគោរពវិន័យហ្នឹង?

**ឆ៖** គាត់បានខូចនារីនៅខាងក្រៅ ហើយក៏គេដាក់គុកទៅវិញ។

**ស៖** លោកភ្លេចឈ្មោះគាត់ហើយ ឬក៏យ៉ាងម៉េច ឬក៏លោកអាចផ្តល់ឈ្មោះបដិវត្តន៍គាត់បានទេនៅសម័យនោះ គាត់ឈ្មោះអីដែរ?

**ឆ៖** បាទ ឈ្មោះ សឿង។

**ស៖** តើឈ្មោះ តាដាំ នេះ លោកស្គាល់ឈ្មោះ តាដាំ ហ្នឹងទេ?

**ឆ៖** បាទ តាដាំ ហ្នឹងមួយ សឿង មួយ បាទ។

**ស៖** ឥឡូវ ខ្ញុំចូលមកនិយាយព័ត៌មានលម្អិតអំពីមុខងារ និងតួនាទីរបស់បក្ខជន។ លោកបាននិយាយអំពីផ្នែករដ្ឋបាល។ អ៊ីចឹង តើបក្ខជនជាអ្នកទទួលខុសត្រូវខាងរដ្ឋបាលដែរឬទេ ខាងគ្រប់គ្រង

ឬក៏ជាអ្នកចុះបញ្ជី សរសេរសំបុត្រអីជាដើម ឬក៏អ្នកចុះបញ្ជីអ្នកទោសជាដើមនោះ?

[១៥:១៦:២៩]

**ឆ៖** កាលនោះ កិច្ចការអស់ទាំងហ្នឹង ខ្ញុំអត់សូវបានដឹងដែរ ពីព្រោះខ្ញុំនៅក្មេង បាទ។

**ស៖** អ្នកធ្វើការជាមួយលោកម្នាក់ឈ្មោះ ស៊ីម នៅក្នុងចម្លើយឯកសារ D40/20 នៅទំព័រខ្មែរ គឺ00165330 ហើយជាភាសាបារាំង គឺ00524319, ជាភាសាអង់គ្លេសគឺ 00433570។ ស៊ីម គាត់និយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "មានឈ្មោះ ឌុច ដែលជាមេទទួលបន្ទុកខាងចុះបញ្ជី ហើយនិងខាងឯកសារ"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងលោកបាននិយាយពីឈ្មោះ ឌុច ដែលធ្វើការនៅស្រុក តើ ឌុច នេះ មានមុខងារជាក់លាក់ណាមួយ នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹងដែរឬទេ?

**ឆ៖** ឃើញគាត់ចូលរួមជាលើករាល់ខែ ប៉ុន្តែខ្ញុំអត់បានហ៊ានមើលមុខគេទេ ឌុច ហ្នឹង បាទ។

**ស៖** ដើម្បីឲ្យច្បាស់លាស់ លោកបាននិយាយអំពី ឌុច ម្នាក់ទៀត ដែលជាអ្នកយាមដែរ ហើយនិង ឌុច ម្នាក់ទៀតមកពីស្រុក។ តើគេបែងចែកគាត់ឲ្យដាច់ កុំឲ្យច្រឡំ ឌុចណា ឌុចមួយ និងឌុច មួយទៀតនោះ ដោយគាត់ធ្វើម៉េចដើម្បីកុំឲ្យច្រឡំគ្នា?

**ឆ៖** ឌុច មួយមកពីស្រុក, ឌុច មួយជាផ្នែកការពារ ប៉ុន្តែគេឲ្យវាយអង្គុលីលេខ។

**ស៖** តើ ឌុច មកពីស្រុកហ្នឹងគាត់ចេះវាយអង្គុលីលេខដែរឬទេ? គាត់វាយខ្លួនឯង ឬក៏ឌុច មួយទៀតទេ ជាអ្នកវាយអង្គុលីលេខនោះ?

**ឆ៖** បាទ គេចេះវ៉ទាំងពីរនាក់។

**ស៖** អ៊ីចឹងបើសិនខ្ញុំមិនច្រឡំទេ គឺថាមាន ឌុច តូចដែលជាអ្នកវាយអង្គុលីលេខ។ អ៊ីចឹងលោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១៥:១៩:២៧]

**ឆ៖** តែធ្វើការជាប់លាប់សព្វថ្ងៃហ្នឹងមានតែ ឌុច តូចទេ។ ពេលម្តងម្កាល ឌុច ធំហ្នឹងបាទ។

**ស៖** លោកបានឆ្លើយនៅក្នុងឯកសាររបស់លោកគឺ ឯកសារ E319.1.33 នៅចម្លើយ៥៦ គឺថានិយាយពីសំបុត្រដែលលោកយកទៅស្រុក ក្នុងឋានៈលោកជានីរសារនោះ គឺថាសំបុត្រទាំងអស់នេះ គឺជាសំបុត្រ ជារបាយការណ៍លើអ្នកទោស ឬក៏ចម្លើយសារភាព។ តើត្រឹមត្រូវដែរឬទេ?" លោកឆ្លើយថា "បាទ ហ្នឹងហើយត្រឹមត្រូវ"។ អ៊ីចឹងបានន័យថានៅក្នុងចម្លើយរបស់លោកនោះ បើបង្ហាញឲ្យឃើញថា លោកដឹងថាសំបុត្ររបស់លោកយកទៅស្រុកហ្នឹងជាអ្វី? អ៊ីចឹងសួរថាហេតុអីបានលោកដឹងថា ខ្លឹមសារ

នៅក្នុងសំបុត្រដែលលោកយកទៅស្រុកហ្នឹង សំបុត្រហ្នឹងមានខ្លឹមសារយ៉ាងណាយ៉ាងណីនោះ ឬជាចម្លើយសារភាពអីជាដើមហ្នឹង?

**ឆ៖** សំបុត្រនេះ ខ្ញុំគ្រាន់តែយក ពិតជាត្រឹមត្រូវហើយ តែខ្ញុំមិនបានបើកមើលទេ គឺថាបើបើកមើលគឺស្លាប់ គេនិយាយប៉ុណ្ណឹង។

**ស៖** តួនាទីមួយទៀតដែលខ្ញុំចង់និយាយ គឺទាក់ទងនឹងតួនាទីរបស់បក្ខជនទាំងប្រាំមួយនាក់ហ្នឹង ចង់ដឹងថាតើគាត់ ការងាររបស់គាត់ដែលត្រូវបំពេញហ្នឹង ក្នុងការសួរចម្លើយអ្នកទោសហ្នឹងមានអ្វីខ្លះ? អ៊ីចឹងខ្ញុំសូមអានអ្វីដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺឯកសារD40/20 ជាភាសាខ្មែរគឺ 00165354, ជាភាសាបារាំងគឺ 00490908, ជាភាសាអង់គ្លេសគឺ 00223210។ ខ្ញុំសូមដកស្រង់៖ “តើអ្នកធ្វើការនៅក្នុងមន្ទីរនោះមានប៉ុន្មាននាក់ មេហើយនិងកូនចៅ? ចម្លើយ៖ ទាំងអស់គ្នាយើងមាន១២នាក់។ សំណួរ៖ “តើគាត់ឈ្មោះអ្វីខ្លះ?” ចម្លើយរបស់លោក គឺលោកឆ្លើយថា “គឺ អាន់, ពេញ, ចេង, ឈៀង, មឿន, ឈឿន, ឌុច, សាំង, ស៊ីម, អ៊ួក, ទូច ហើយនិងចុងក្រោយគេហ្នឹងគឺខ្ញុំផ្ទាល់ហ្នឹងឯង”។ សំណួរបន្ទាប់ទៀតគឺថា៖ “តើនៅក្នុងមន្ទីរហ្នឹង បុគ្គលិកហ្នឹងត្រូវបែងចែកជាផ្នែកៗដើម្បីធ្វើការងាររបស់ខ្លួន?” ចម្លើយលោកឆ្លើយថា “បាទ មានផ្នែកសួរចម្លើយ និងផ្នែកយាម”។ សំណួរបន្ត៖ “តើអ្នកដែលនៅក្នុងផ្នែកសួរចម្លើយ អ្នកណា -- មានអ្នកណាខ្លះ? ចម្លើយ៖ គឺមាន អាន់, ចេង, ហើយនិង ពេញ”។ អ៊ីចឹងឲ្យលោកឈ្មោះបី គឺមាន អាន់, ចេង, ហើយនិង ពេញ ដែលស្ថិតនៅក្នុងចំណោមមនុស្សបក្ខជនទាំងប្រាំមួយនាក់។ តើៗបក្ខជនផ្សេងទៀតនេះ មានតួនាទីអ្វីដែរឬទេ នៅក្នុងការសួរចម្លើយ? ឬក៏គេអត់មានតួនាទីអ្វីទេនៅក្នុងសួរចម្លើយអ្នកទោសនោះ?

[១៥:២៣:៣០]

**ឆ៖** ក្នុងហ្នឹងគេផ្លាស់ប្តូរគ្នាបាទ។

**ស៖** អ៊ីចឹងបក្ខជនទាំងប្រាំមួយនាក់នេះផ្លាស់វេនគ្នាដើម្បីសួរចម្លើយអ្នកទោស។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើនៅពេលសួរចម្លើយ អង្គភាពអ្នកយាមនោះមានតួនាទីអ្វីទេក្នុងការយាមកន្លែងសួរចម្លើយ ឬក៏ក្នុងការយកអ្នកទោសមកកន្លែងសួរចម្លើយ?

**ឆ៖** បាទ គ្នាគេទាំងប្រាំមួយរូបហ្នឹង ចាត់ចែងគ្នាគេ។

**ស៖** បាទ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីក្រុមៗអ្នកដឹកនាំដែលជាពួកបក្ខជននេះ ទាក់ទងទៅនឹងការសម្លាប់អ្នកទោស។ ខ្ញុំសូមដកស្រង់ឯកសារពីរ គឺទី១ ឯកសារ D40/23 នៅទំព័រជាភាសាខ្មែរគឺ 00165335, ជាភាសាបារាំងគឺ 00490909, ជាភាសាអង់គ្លេសគឺ 00223211។ បាទ សំណួរគឺដូចតទៅនោះ៖ “អ្នកដែលស្ថិតនៅក្នុងផ្នែកសម្លាប់អ្នកទោស តើលោកដឹងថា ពួកគេហ្នឹងមកពីណាដែរឬទេ?” ចម្លើយរបស់លោក៖ “គឺផ្នែកហ្នឹងមានបក្ខជនប្រាំមួយនាក់នៅក្នុងផ្នែកហ្នឹង។ សំណួរ៖ “តើគាត់មានឈ្មោះអីខ្លះ?” ចម្លើយរបស់លោកគឺ៖ “ឈ្មោះ អាន់, ពេញ, ចេង, ឈៀង, មឿន និង ឈឿន”។ សូមបញ្ចប់ការដកស្រង់។

[១៥:២៦:០១]

នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកមួយទៀត គឺថាមានចម្លើយរបស់លោកមួយដែលខុសគ្នាពីនេះបន្តិច ខ្ញុំនឹងដកស្រង់គឺឯកសារ D319.1.33។ សំណួរលេខ១៩៣ លោក -- សំណួរសួរដូច្នេះ៖ “តើមានតែ ឃន ហើយនិង រស់ ទេឬដែលជាពេជ្ឈឃាដ ដែលជាអ្នកសម្លាប់នៅទីនោះ បើតាមលោកដឹង? ចម្លើយ៖ មានមនុស្សប្រាំនាក់ដែលជាបក្ខជននោះ ជាអ្នកសម្លាប់គឺមានឈ្មោះ ឈៀង, ពេញ, មឿន, រស់ និង ឃន។ សំណួរ១៩៦៖ ហេតុអីបានលោកដឹងថា ពេញ, ឈៀង, រស់, ឃន ហើយនិង មឿន ហ្នឹងជាអ្នកសម្លាប់មនុស្ស?” ចម្លើយរបស់លោក៖ “ព្រោះមានមនុស្សតែប៉ុណ្ណឹងនៅក្នុងមន្ទីរឃុំឃាំង”។ ហើយមានចម្លើយមួយទៀត៖ “ថាតើៗលោកមានដឹងថា មនុស្សទាំងប្រាំនាក់ហ្នឹងសម្លាប់មនុស្សដែរឬទេ?” ចម្លើយលោកឆ្លើយថា៖ “អត់ដឹងទេ”។ អ៊ីចឹងខ្ញុំសូមឲ្យលោកបញ្ជាក់ថា តើអ្នកណាជាអ្នកទទួលបន្ទុកខាងសម្លាប់អ្នកទោស? តើជាអ្នកក្រុមអ្នកគ្រប់គ្រងដែលមានបក្ខជនទាំងប្រាំមួយនាក់ហ្នឹង បូកជាមួយនឹងឈ្មោះ ឃន ហើយនិងឈ្មោះ រស់ ហ្នឹង ឬក៏ៗមានឈ្មោះបុគ្គលផ្សេងទៀតដែលលោកអាចរៀបរាប់បាន ក្រៅពីអ្នកទាំងប៉ុន្មាននាក់ដែលខ្ញុំនិយាយអម្បាញ់មិញនេះ?

**ឆ៖** បាទ ក្រៅពីនោះ ខ្ញុំអត់ស្គាល់មែន ឃន ហើយនិង រស់ ខ្ញុំអត់ស្គាល់ទេបាទ។

[១៥:២៨:១៧]

**ស៖** តើនៅពេលណាមួយ នៅក្នុងពេលដែលលោកធ្វើការនៅក្នុងមន្ទីរក្រាំងតាចាន់នុំុង អ្នកធ្វើការជាមួយលោក គឺថានៅក្នុងចំណោមអ្នកយាមទាំងប្រាំមួយនាក់ហ្នឹង មានធ្លាប់បានទទួលបញ្ជាពីតាអាន់ ឬក៏ តាពេញ ឲ្យធ្វើ -- កាន់តួនាទីអ្វីមួយក្នុងការសម្លាប់អ្នកទោសដែរឬទេ?

**ឆ៖** បាទ ខ្ញុំចំពោះរូបខ្ញុំផ្ទាល់គ្មាន ព្រោះគេថាខ្ញុំក្មេងពេកបាទ។

**សៈ** ខ្ញុំមិនបានចោទប្រកាន់លោកពីរឿងអ្វីនោះទេ ខ្ញុំដឹងថាកាលណោះលោកនៅក្មេងហើយ ក៏ប៉ុន្តែក្នុងចំណោមអ្នកទាំងប្រាំនាក់ដែលក្នុងក្រុមអ្នកយាមហ្នឹង តើមានអ្នកណាដែលបានទទួលបញ្ជាឱ្យចូលរួមក្នុងការសម្លាប់អ្នកទោសដែរឬទេ?

**ផៈ** ក្នុងអំឡុងនោះខ្ញុំអត់បានដឹងទេ ពីព្រោះខ្ញុំខាងផ្នែករត់សំបុត្រមកក្រៅ តែនេះគេបញ្ជូនខ្ញុំមកក្រៅបាទ។

**សៈ** លោកបាននិយាយថាលោកក្មេងជាងគេនៅក្នុងក្រុមអ្នកយាមហ្នឹង អ៊ីចឹងគេមិនបានសុំឱ្យលោកចូលរួមកាប់សម្លាប់ទេ។ តើមានប្រភេទការងារអីផ្សេងទៀតដែលគេមិនឱ្យលោកធ្វើដែរឬទេដោយសារលោកក្មេងពេក? ឧទាហរណ៍ដូចជាការងារខាងយាមអ្នកទោស ឬក៏ការងារផ្សេងទៀតនៅមន្ទីរក្រាំងតាចាន់ហ្នឹង មានគេប្រគល់ការងារផ្សេងឱ្យលោកធ្វើទេ ដែលគេមិនអាចឱ្យលោកធ្វើ ដោយសារលោកក្មេងពេក?

**ផៈ** បាទ គេឱ្យយាមខាងក្រៅ។

[១៥:៣០:៣០]

**សៈ** បាទឥឡូវនេះ ខ្ញុំព្យាយាមចង់ដឹងពីអ្វីដែលក្រុមអ្នកយាមទាំងនោះធ្វើ។ តើអ្នកយាមទាំងប្រាំមួយនាក់ហ្នឹងស្ថិតនៅក្នុងបញ្ជាបក្ខជនទាំងអស់ហ្នឹង ឬក៏យ៉ាងម៉េច? ឬក៏តាអាន់ ហើយនិងសមាជិកផ្សេងទៀតនៃក្រុមគ្រប់គ្រងហ្នឹង បញ្ជាឱ្យពួកលោកដែលជាអ្នកនៅក្រោមបង្គាប់ឱ្យយាមអ្នកទោសនៅខាងក្រៅ ហើយនិងធ្វើយ៉ាងណាកុំឱ្យមានអ្នកទោសរត់រួច។ គេបញ្ជាឱ្យលោកធ្វើអ៊ីចឹងដែរទេ?

**ផៈ** បាទ។

**សៈ** តើគេមានសុំឱ្យគ្នាលោកហ្នឹងយាមអ្នកទោសនៅក្នុងមន្ទីរឃុំឃាំងដែរឬទេ?

**ផៈ** ចាប់ផ្ដើមគេធ្វើការ គេបញ្ជូនខ្ញុំមកក្រៅ ឱ្យយាមខាងក្រៅបាទ។

**សៈ** ខ្ញុំត្រឡប់មកនិយាយអំពីចំណុចនេះនៅថ្ងៃស្អែកទៀត តើគេមានបានសុំឱ្យគ្នារបស់លោកដែលជាអ្នកយាមហ្នឹងនាំអ្នកទោសថ្មីដែលមកដល់មន្ទីរក្រាំងតាចាន់ មកដល់បរិវេណខាងក្រៅនៃមន្ទីរហ្នឹង តើគេមានឱ្យក្រុមលោកហ្នឹងនាំអ្នកទោសទាំងអស់ហ្នឹងទៅអគារឃុំឃាំងដើម្បីដាក់ខ្នោះពួកគេដែរឬទេ?

**ផៈ** បាទអត់ទេ តែបក្ខជនគ្នាគេប្រាំមួយរូបបាទ។

**សៈ** តើគេមានបញ្ជាឱ្យគ្នាលោកហ្នឹង ជាក្រុមនៅក្រោមបង្គាប់គេហ្នឹង ខ្ញុំនិយាយពីលោកទេ

និយាយពីគ្នាលោក ថាគេមានបញ្ហាឲ្យពួកគាត់យកអ្នកទោសទៅកន្លែងសួរចម្លើយ ហើយនិងយកចេញទៅវិញក្រោយពីពេលសួរចម្លើយដែរឬទេ?

**ឆ៖** បាទ គេអត់ប្រើយើងកងការពារទេ បាទ។

**ស៖** បាទ អ៊ីចឹងអ្នកណាអ្នកនាំអ្នកទោសទៅកន្លែងសួរចម្លើយ ហើយបន្ទាប់មកអ្នកណាជាអ្នកនាំទៅអគារឃុំឃាំងវិញនៅពេលសួរចម្លើយហើយ។ អ៊ីចឹងសួរថា ជាអ្នកយាម ជាអ្នកទោសដូចគ្នា ជាអ្នកនាំ ឬក៏ជាបក្ខជនជាអ្នកនាំ អ្នកនៅក្នុងគណៈគ្រប់គ្រងមន្ទីរហ្នឹងជាអ្នកនាំ?

**ឆ៖** បាទ ផ្នែកគេបក្ខជនគេជាអ្នកនាំតែម្តង ទាំងចេញ ទាំងចូល។

[១៥:៣៤:០១]

**ស៖** អ៊ីចឹងសង្ខេបឲ្យខ្លី បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺថាទាក់ទងទៅនឹងការគ្រប់គ្រង ហើយនិងការសួរចម្លើយអ្នកទោស អ្នកសម្លាប់អ្នកទោសនោះ គឺសុទ្ធតែជាក្រុមខាងគ្រប់គ្រងហ្នឹងទេ ដែលធ្វើភារកិច្ចហ្នឹង ហើយនៅក្នុងពេលខណៈនោះ ក្រុមអ្នកយាមនោះមិនបានធ្វើអ្វីនោះទេ។ តើការយល់ឃើញរបស់ខ្ញុំនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ។

**ស៖** បាទ ខ្ញុំសូមចោទសំណួរពីរបីទាក់ទងទៅនឹងបុគ្គលដែលលោកនិយាយថា ពាក់ព័ន្ធនឹងមន្ទីរក្រាំងតាចាន់។ លោកនិយាយនេះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ដូចជាឈ្មោះ ឌុច ហើយនិងឈ្មោះ ភី។ ហើយលោកបាននិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទី១ គឺឯកសារ D40/23 នៅចុងក្រោយនៅកំណត់ហេតុស្តាប់ចម្លើយហ្នឹង ខ្ញុំមិនបាច់ផ្តល់លេខ ERN ទេ។ "នៅក្នុងពេលដែលលោកធ្វើការនៅមន្ទីរនោះ តើលោកធ្លាប់ឃើញអ្នកដឹកនាំជាន់ខ្ពស់បានមកត្រួតពិនិត្យមន្ទីរហ្នឹងដែរឬទេ?" ចម្លើយរបស់លោកគឺឆ្លើយថា "មានតែឈ្មោះ ភី និង ឌុច ទេ គាត់ហ្នឹងធ្វើការនៅស្រុកត្រាំកក់ គាត់ឧស្សាហ៍ទៅកន្លែងនោះដោយជិះម៉ូតូ ឬក៏ដោយជិះឡាន"។ បញ្ចប់ការដកស្រង់។ ហើយលោកអម្បាញ់មិញនេះ លោកបានបញ្ជាក់ថា អ្នកទាំងពីររូបនេះទៅមន្ទីរហ្នឹង ហើយលោកបានប្រាប់ផងដែរថា ឌុច ហ្នឹងមានតួនាទីជាប្រធានយុវជន។ តើ ឌុច នោះគាត់នៅក្រាំងតាចាន់តែម្តង? ឌុចធំនុះណ៎ា គាត់ស្នាក់នៅក្រាំងតាចាន់ហ្នឹងតែម្តង ឬក៏គាត់មកហ្នឹងតែម្តងម្កាលទេ ដោយពេលទេ?

**ឆ៖** បាទ ឌុចធំហ្នឹងមកម្តងម្កាលទេបាទ។

**ស៖** ឌុច តូចដែលជាអ្នកធ្វើការជាមួយលោកហ្នឹង នៅក្នុងសវនាការនេះ គឺឯកសារ D232/93

នៅចម្លើយទី៤ របស់គាត់ គាត់ឆ្លើយនៅមុខតុលាការយើងនេះ គាត់និយាយថាគាត់ -- "ខ្ញុំនៅចាំថា ប្រធានមន្ទីរហ្នឹងឈ្មោះ អាន់ ហើយអនុប្រធានឈ្មោះ ឌុច" ។ សូមបញ្ចប់ការដកស្រង់។ តើលោកមិនយល់ស្របនឹង ឌុចតូចទេឬ ទាក់ទងទៅនឹងតួនាទីរបស់ ឌុចធំ ថាគាត់ហ្នឹងជាអនុប្រធានរបស់ តាអាន់ នៅមន្ទីរក្រាំងតាចាន់?

**ឆ៖** បាទ ខ្ញុំមិនសូវដឹងដែរបាទ។

[១៥:៣៧:០៨]

**ស៖** បាទ តាមលោកដឹង ឬក៏តាមលោកសង្កេតនោះ តើហេតុអ្វីបានជាឌុចធំនោះ មកក្រាំងតាចាន់? កាលមកហ្នឹងដើម្បីពិនិត្យមើលគ្រប់គ្រង់ ឬសង្កេត ឬធ្វើការស៊ើបអង្កេត ឬក៏មកគ្រប់គ្រងផ្នែករដ្ឋបាលនៃមន្ទីរហ្នឹង ឬក៏យ៉ាងណា? លោកអាចដឹងទេថាហេតុអីបានគាត់មកមន្ទីរក្រាំងតាចាន់ហ្នឹងញឹកញាប់?

**ឆ៖** បាទ រឿងអស់ទាំងនេះ ខ្ញុំអត់សូវដឹងផងបាទ កាលនុងបាទ។

**ស៖** តើលោកធ្លាប់បានឃើញ ឌុច ធំហ្នឹងមកមន្ទីរក្រាំងតាចាន់រហូតដល់ចុងឆ្នាំ១៩៧៨ ដើមឆ្នាំ១៩៧៩ ដែរឬទេ?

**ឆ៖** មករយៈពេល ជួនកាលមួយខែអ៊ីចឹង គេមកពីរដងបីដងអ៊ីចឹងទៅ បាទក្នុង១៩៧៨ហ្នឹងឃើញមកញឹកញាប់បាទ។

**ស៖** អ៊ីចឹង លោកចង់និយាយថាគាត់មកមន្ទីរហ្នឹង គឺនៅពេលចុងបញ្ចប់នៃមន្ទីរសន្តិសុខហ្នឹងហើយ។ ចង់និយាយថាអ៊ីចឹង ឬក៏ម៉េច? គាត់មកពេលជិតចប់ហើយទេ អ៊ីចឹងឬ?

**ឆ៖** បាទ ក្នុងនេះ ខ្ញុំមិនបានដឹងថាគាត់មកមានផែនការអីទេ ពីព្រោះថាគាត់ក្នុង៧៨ ហ្នឹងឃើញមកញឹកញាប់បាទ រហូតដល់ស្នាក់នៅហ្នឹងមួយយប់ពីរយប់ក៏មានដែរ។

**ស៖** បាទ ឥឡូវខ្ញុំសូម -- បាទ ខ្ញុំសូមជម្រាបជូនលោកថា នៅក្នុងសំណុំរឿងមានកំណត់ហេតុស្តាប់ចម្លើយរបស់ ឌុច គឺឌុចធំហ្នឹង ដែលមានលេខឯកសារគឺ E3/4627។ នៅទំព័រជាភាសាខ្មែរគឺ 00163492, ជាភាសាបារាំងគឺ 00651258, ជាភាសាអង់គ្លេសគឺ 00223475។ គាត់និយាយថា គាត់បានមកពិនិត្យស្ថានភាពហ្នឹង--

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងថាតើមានការ -- ដូចអ្វីដែលសហព្រះរាជអាជ្ញាយោងនោះទេ ដោយសារមានបុគ្គល

មួយទៀតឈ្មោះ ឌុចធំ។ បើសិនណាជាសហព្រះរាជអាជ្ញាមិនសួររបៀបផ្សេងទៀត ខ្ញុំសូមជំទាស់ទៅនឹងការតាំងសំណួរបែបនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ជាមួយសាក្សីនេះ យើងពិបាកបង្កើតមូលដ្ឋាន។ តើ អ៊ីចឹងខ្ញុំសួរលោកថាឈ្មោះ អៀប ឌុច នេះ លោកស្គាល់គាត់ទេ បើធៀបនឹងឌុចធំហ្នឹងជាមនុស្សតែមួយ ឬក៏មនុស្សពីរនាក់ខុសគ្នា?

**លោក វ៉ាន់ សឿន៖**

**ឆ៖** ឌុច នៅក្រាំងតាចាន់ហ្នឹងពីរ។ បាទ ឌុចធំមួយ ឌុចតូចមួយ បាទ។ មួយ ឌុច ហៅ សាវ៉ាត់មួយឈ្មោះ ឌុច តែម្តង បាទ។

**ស៖** បាទ លោកសាក្សី ខ្ញុំសូមសួរថាតើលោក ដោយផ្ទាល់នេះ លោកធ្លាប់ឃើញតួកុន គីម ណូវ៉ា ហើយនិង ណុប ណែម នៅក្រាំងតាចាន់ដែរឬទេ? ឬក៏លោកធ្លាប់ឮគេនិយាយពីតួកុនពីររូបនេះដែរឬទេ?

[១៥:៤១:៣៨]

**ឆ៖** បាទ អត់ទេ។

**ស៖** បាទសំណួរមួយទៀត។ បាទ ទាក់ទងនឹង តាភី លោកបាននិយាយអម្បាញ់មិញនេះ គឺថាគាត់មកពីស្រុកត្រាំកក់ដើម្បីមកមន្ទីរក្រាំងតាចាន់។ បើតាមលោកដឹង តើគាត់មានមុខងារ តួនាទី ហើយទំនាក់ទំនងគាត់ហ្នឹងជាមួយនឹងមន្ទីរក្រាំងតាចាន់ហ្នឹងយ៉ាងម៉េចដែរ? គាត់មានតួនាទីអ្វីនៅថ្នាក់ស្រុក មានមុខងារអ្វីដែរនៅថ្នាក់ស្រុកនោះបាទ?

**ឆ៖** បាទ តាភី កំបាក់ហ្នឹង ខ្ញុំក៏អត់បានថាគាត់មានមុខនាទីអ្វីដែរ ប៉ុន្តែប៉ុនក្នុងថា មន្ទីរក្នុងស្រុកត្រាំកក់ គាត់ក្តាប់ទាំងអស់បាទ។

**ស៖** តើគាត់អាចមានតួនាទីផ្នែកសន្តិសុខ ដែរឬទេ? ឬក៏លោកមិនដឹងអ្វីទាំងអស់?

**ឆ៖** បាទ អត់ដឹងអ្វីទាំងអស់។

**ស៖** បាទ អម្បាញ់មិញនេះ ខ្ញុំបានដកស្រង់ផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក ដែលលោកនិយាយអំពីលោក តាឃន ហើយនិង តារស់ ដែលសម្លាប់មនុស្ស។ ហើយលោកៗនិយាយថាលោកមិនដែលបានឮគេនិយាយពីបុគ្គលទាំងពីរនាក់នេះទេ។ តើលោកអាចបញ្ជាក់បានដែរឬទេថាបុគ្គលពីររូបនេះ មិនដែលបានមកមន្ទីរក្រាំងតាចាន់ដើម្បីសម្លាប់មនុស្សទេ? លោករក្សាចម្លើយរបស់

លោកទេ?

**ឆ៖** បាទ តាឃន និងតារស់ហ្នឹង ខ្ញុំអត់ដែលស្គាល់មែនបាទ។ ក្រែងលោគេមកយប់យ៉ាងម៉េច ខ្ញុំអត់ដឹងទេ ប៉ុនថាបើថ្ងៃខ្ញុំអត់ដែលឃើញទេ។

**សៈ** បាទ ដូច្នេះលោកនិយាយថា គ្មានអ្នកណាមកពីស្រុកដើម្បីសម្លាប់មនុស្សទេ បើតាមលោកដឹង។ អ៊ីចឹងគឺថាមានតែបក្ខជនទាំងប្រាំមួយនាក់ទេដែលសម្លាប់មនុស្សនៅក្រាំងតាចាន់នេះ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

[១៥:៤៤:៣២]

**សៈ** បាទឥឡូវនេះ ខ្ញុំសូមមិននិយាយអំពីតួនាទីរបស់លោកជានីរសារនៅមន្ទីរក្រាំងតាចាន់។ គឺនីរសាររត់សំបុត្រពីក្រាំងតាចាន់ទៅស្រុកត្រាំកក់។ តើលោកជានីរសារតែមួយទេ ពីនីរសារក្រាំងតាចាន់ដែលយករត់សំបុត្រពីក្រាំងតាចាន់ទៅស្រុកត្រាំកក់តែម្នាក់ឯងទេ ឬក៏មាននីរសារផ្សេងទៀត?

**ឆ៖** បាទ មានពីរនាក់ មួយឈ្មោះ មឿន បក្ខជនហ្នឹងមួយ ហើយនិងខ្ញុំបាទ។

**សៈ** តើ មឿន ហ្នឹងគាត់ជិះកង់ទៅមន្ទីរស្រុកអង្គរកាដែរឬទេ?

**ឆ៖** បាទ កាលសម័យនោះមានតែកង់ទេបាទ ហើយនិងសេះ។

**សៈ** ក្រៅពីលោកហើយនិង មឿន តើលោកមានដឹងថាតើកម្មាភិបាលដែលធ្វើការនៅស្រុកឧទាហរណ៍ដូចជា ឌុចធំជាដើម ឬក៏ តាភី គាត់យកសំបុត្រមកឲ្យមន្ទីរក្រាំងតាចាន់ដែរ ពេលដែលពួកគាត់មកមន្ទីរក្រាំងតាចាន់? លោកធ្លាប់ឃើញពួកគាត់ប្រគល់សំបុត្រឲ្យ តាអាន់ ដែរឬទេ ពេលពួកគាត់មកមន្ទីរក្រាំងតាចាន់នោះ?

**ឆ៖** បាទ ខាងក្នុងខ្ញុំមិនសូវដែលនៅផង។ បាទ អត់ដែលបានឃើញទេ។

**សៈ** <តើ តាអាន់ តាឌុច តាពេញ ឬ ឆេង ធ្លាប់ប្រគល់សំបុត្រឲ្យលោកដោយផ្ទាល់ ដើម្បីយកទៅស្រុកអង្គរកាដែរឬទេ?>

**ឆ៖** បាទ ជួនកាលគេធ្វើដំណើរទៅផ្ទះគ្រួសារគេ គេអាចយកទៅអ៊ីចឹង ជួនកាលក៏គេយកមកហុច ខ្ញុំខាងក្រៅតែម្តងបាទ។

**សៈ** នៅពេលដែលលោករត់សំបុត្រដែលថ្នាក់ដឹកនាំប្រគល់ឲ្យលោក។ អ៊ីចឹងលោកយកទៅប្រគល់ទៅមន្ទីរស្រុកនៅអង្គរកាហ្នឹងដោយផ្ទាល់ដៃ ឬក៏ប្រគល់ឲ្យចៅហ្វាយស្រុកផ្ទាល់ដៃ។ លោក

និយាយពីមន្ទីរពាណិជ្ជដែរនៅអង្គរកាហ្នឹង។ តើលោកនាំយកសំបុត្រ ប្រគល់សំបុត្រទៅមន្ទីរពាណិជ្ជនៅអង្គរកាហ្នឹងញឹកញាប់ជាងឬក៏យ៉ាងម៉េច?

**ឆ៖** បាទជួនកាល១ថ្ងៃម្តង ជួនកាល៣ថ្ងៃម្តង។ ហើយប្រគល់ហ្នឹងមិនផ្ទាល់ដៃថៅហ្វាយស្រុកទេ គឺមាននីរសារស្រុកផ្ទាល់របស់គេតែម្តងបាទ ប្រគល់ឲ្យគេ។

**សៈ** តើមន្ទីរពាណិជ្ជកម្មនៅអង្គរកាហ្នឹងស្ថិតនៅក្នុងអគារតែមួយទេ បើធៀបទៅនឹងមន្ទីរស្រុកហ្នឹង ឬក៏មានចម្ងាយពីគ្នាប៉ុន្មានដែររវាងមន្ទីរទាំងពីរហ្នឹង មន្ទីរពាណិជ្ជ ហើយនិងមន្ទីរស្រុក?

[១៥:៤៨:៤២]

**ឆ៖** កាលណោះ ខ្ញុំមិនដឹងមន្ទីរស្រុកច្បាស់ដែរ ប៉ុន្តែខ្ញុំនាំទៅតែត្រឹមមន្ទីរពាណិជ្ជកម្ម ព្រោះស្រុកវានៅច្រើនកន្លែង ពីព្រោះមួយនៅលាយបូរ កន្លែងមួយនៅត្រពាំងធំ។ បាទ គ្មានធ្វើសាលាស្រុកទេ នៅផ្ទះៗគេតែម្តងបាទ។

**សៈ** អ៊ីចឹងនៅពេលយើងនិយាយពីកន្លែងអង្គរកានេះ អ៊ីចឹងអង្គរកានេះស្ថិតនៅក្នុងឃុំណា? ហើយនៅលើផ្លូវណា?

**ឆ៖** អង្គរកាស្ថិតនៅជាប់ស្ពាននិងផ្សារសព្វថ្ងៃ។ បាទ ស្ថិតនៅឃុំត្រពាំងធំខាងត្បូង។

**សៈ** អ៊ីចឹងថា តើកន្លែងហ្នឹងនៅខាងលិចអង្គតាសោមឆ្ងាយដែរ ហើយបើសិនឆ្ងាយមែននោះនៅចម្ងាយប៉ុន្មានគីឡូម៉ែត្រពីនុំង?

**ឆ៖** ពីផ្សារអង្គតាសោម ទៅផ្សារអង្គរកាប្រហែលជា១០គីឡូម៉ែត្រ។

**សៈ** ក្រៅពីសំបុត្រដែលលោកយកទៅស្រុក តើលោកមានរត់សំបុត្រទៅកន្លែងផ្សេងទៀតទេ ឧទាហរណ៍ដូចនៅក្នុងឃុំផ្សេងទៀត ឬក៏នៅមន្ទីរសន្តិសុខផ្សេងទៀតដែលស្ថិតនៅក្នុងស្រុកត្រាំកក់ដែរឬទេ? ឬក៏សហករណ៍អីផ្សេងទៀត?

**ឆ៖** បាទ អត់ទេ។ ខ្ញុំរត់តែត្រឹមពីក្រាំងតាចាន់មកពាណិជ្ជកម្មស្រុកត្រាំកក់តែម្តង បាទ។

**សៈ** លោកបានឆ្លើយថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកៗនិយាយថា"គុកអង្គរកា" ខ្ញុំត្រឡប់មកនិយាយពីចំណុចនេះពេលក្រោយ។ ខ្ញុំសួរថាតើកន្លែងមន្ទីរគុកអង្គរកានេះ នៅកន្លែងណាដែរ? នៅចម្ងាយប៉ុន្មានពីមន្ទីរស្រុកអីជាដើមនេះ?

[១៥:៥១:៣២]

**ឆ៖** គេធ្វើកន្លែងដាក់សម្រាលទោសនៅខាងលិចផ្សារអង្គរកាសព្វថ្ងៃ ចម្ងាយប្រហែលជាបី-

បួនរយម៉ែត្រពីផ្សារអង្គរកាសព្វថ្ងៃ បាទ។

**សះ** តើមន្ទីរឃុំនេះនៅជិតមន្ទីរពាណិជ្ជកម្ម ឬក៏នៅជិតមន្ទីរស្រុកដែរឬទេ? ហើយនៅចម្ងាយប៉ុន្មានដែរពីមន្ទីរទាំងពីរនេះ មន្ទីរស្រុក ហើយនិងមន្ទីរពាណិជ្ជកម្មនេះ?

**ធះ** ចម្ងាយពីមន្ទីរពាណិជ្ជកម្មប្រហែលជាបួន-ប្រាំរយម៉ែត្រទេ បាទ។ មន្ទីរស្រុកពិតប្រាកដអត់មានដឹងកន្លែង បាទ។

**សះ** អម្បាញ់មិញលោកបានឆ្លើយថានៅពេលដែលលោកមានសំបុត្រ -- បើសិនជាលោកបើកសំបុត្រអីហ្នឹង គឺលោកនឹងត្រូវបានគេសម្លាប់។ នៅក្នុងចម្លើយ៤៧ លោកនិយាយថា៖ “លោកមិនដែលបានបើកមើលទេ។ មិនដែលមើលទេ បើសិនជាលោកបើកហ្នឹង លោកត្រូវគេសម្លាប់” គឺនៅក្នុងឯកសារ E319.1.33។ អ៊ីចឹង ខ្ញុំសួរលោកថាតើអ្នកណាគេអ្នកនិយាយប្រាប់លោកថា បើសិនជាបើកសំបុត្រហ្នឹង គេនឹងសម្លាប់លោក ហើយខ្ញុំសួរថា ជាការគំរាមកំហែង គ្រាន់តែកំញើញទេ ឬក៏បើបើកហ្នឹងសម្លាប់មែន?

**ធះ** បាទ កាលសម័យនោះ បើខ្ញុំពិនិត្យទៅ គេមិនគំរាមទេ បើបើកមើលពិតមែន ពិតជាគេសម្លាប់ពិតមែន។

[១៥:៥៣:៥២]

**សះ** បាទ ខ្ញុំសូមអានសម្រង់មួយទៀតនៃឯកសារដដែលហ្នឹង គឺថាឯកសារ E319.1.33។ “សំណួរ៣៤៖ តើសំបុត្រដែលលោករត់ទៅហ្នឹង មានស្រោមដែរឬទេ? ចម្លើយ៖គឺថាគេវាយអង្គុលីលេខ ហើយគេដាក់សំបុត្រ ហើយអត់មានដាក់ -- អត់មានបោះត្រាអីទេ។ គេបិតជ័រ ហើយជួនកាលទៅមានសំបុត្រមួយ ជួនកាលមានសំបុត្រពីរ ហើយនៅក្នុងស្រោមសំបុត្រហ្នឹងបីនៅក្នុងស្រោមសំបុត្រនោះ។ សំណួរថា៖ ម៉េចក៏ដឹងថាគេវាយអង្គុលីលេខ? ចម្លើយ៖ ពីព្រោះថាកាលហ្នឹងមានអង្គុលីលេខមួយនៅមន្ទីរក្រាំងតាចាន់។ អ៊ីចឹងខ្ញុំអត់បានអានសំបុត្រហ្នឹងទាំងអស់ទេ ខ្ញុំក៏ឃើញ -- ខ្ញុំក៏ដឹងថា -- ក៏ឃើញថាគេវាយអង្គុលីលេខនៅក្នុងបន្ទប់ ហើយបន្ទាប់មកទៀតគេដាក់នៅក្នុងស្រោមសំបុត្រ។ សំណួរ៖ ថាតើអ្នកណាជាអ្នកវាយអង្គុលីលេខ? ចម្លើយ៖ ពីដំបូង គឺអាន់។ ប្រធានអាន់ហ្នឹងជាអ្នកសរសេរនឹងដៃទេ បន្ទាប់មក ឲ្យគេវាយអង្គុលីលេខ។ តើលោកធ្លាប់ឃើញអាន់ ហ្នឹង សរសេរសំបុត្រដោយផ្ទាល់នឹងភ្នែកហ្នឹងដែរឬទេ? បាទខ្ញុំឃើញផ្ទាល់ភ្នែក ឃើញគាត់សរសេរទាំងអស់ហ្នឹងនៅក្នុងមន្ទីររបស់គាត់។ ខ្ញុំនៅចម្ងាយប្រហែលជា៧ ឬ៨ម៉ែត្រពីគាត់ ប៉ុន្តែខ្ញុំមិនអាចចូលទៅជិតកន្លែងគាត់ធ្វើការនោះទេ។ ចម្លើយ

៤៥៖ ទេ ខ្ញុំមិនដែលបានអានសំបុត្រនោះទេ ហើយក៏មិនដែលអានពីរបាយការណ៍ដែរ គេហាមមិនឲ្យអានទេ"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងអម្បាញ់មិញនេះលោកចង់និយាយថា លោកគ្រាន់តែជាអ្នកយាមនៅខាងក្រៅទេ។ អ៊ីចឹងប៉ុន្តែកន្លែងនេះឃើញថា លោកនោះបានឃើញគេវាយអង្គុលីលេខសំបុត្រនៅក្នុងការិយាល័យក្នុងមន្ទីរដែល អាន់ –តាអាន់– នោះ គាត់សរសេរដោយដៃដោយខ្លួនឯង។ បន្ទាប់មកផ្ដល់ឲ្យគេវាយអង្គុលីលេខ ហើយលោកបានឃើញហេតុការណ៍ទាំងអស់នេះដោយផ្ទាល់ភ្នែកទៀតផង។ ហើយលោកក៏បាននិយាយអំពីសំបុត្រ ហើយនិងរបាយការណ៍។ លោកអាចផ្ដល់ព័ត៌មានលម្អិតបានទេ ទាក់ទងនឹងអ្វីដែលលោកបានឃើញនៅក្នុងមន្ទីរហ្នឹង កន្លែងដែលគេសរសេរសំបុត្រដោយដៃ គឺថា អាន់ អ្នកសរសេរ ហើយបន្ទាប់មកវាយអង្គុលីលេខដោយ ឌុចតូច។ កាលនោះលោកនៅចម្ងាយ៧-៨ម៉ែត្រពីកន្លែងពួកគាត់ហ្នឹង។ អ៊ីចឹងគឺខ្ញុំសួរលោកថា តើលោកបានឃើញអ្វីខ្លះ ហើយសូមឲ្យផ្ដល់ព័ត៌មានលម្អិតបន្តិចទាក់ទងនឹងចំណុចទាំងអស់នេះ?

[១៥:៥៦:៣៧]

**ឆ៖** បាទ ក្នុងកន្លែងនោះយើងមិនអាចជិតបានទេ ព្រោះយើងក្មេងៗ គេមិនឲ្យទៅជិតគេតែម្ដង ហើយម្យ៉ាងទៀត បង្អួចជុំវិញ មើលឃើញពីក្រៅបង្អួចទៅបាទ។ ឃើញសរសេរហុចតគ្នាបន្តបន្ទាប់បាទ។

**ស៖** តើ ឌុច សារ៉ាត ដែលហៅថា ឌុចតូចនេះ វាយអង្គុលីលេខញឹកញាប់ដែរឬទេ នៅក្នុងមន្ទីររបស់តាអាន់?

**ឆ៖** បាទ វាយរាល់ថ្ងៃបាទ ព្រឹកៗ វាយពេលព្រឹក។

**ស៖** អ៊ីចឹងបានន័យថា ពេលព្រឹកអ៊ីចឹងវាយរយៈពេលប៉ុន្មានទៅ ពីរបីនាទីទេ ឬក៏មួយព្រឹកពេញតែម្ដង បើតាមលោកដឹងពីសម័យនោះ?

**ឆ៖** បាទ សម័យ មានពេលវេលាបាទ។ ខ្ញុំមិនសូវនៅដែរបាទ។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកគឺឯកសារ E319.1.33 នៅសំណួរ៣៦ ដែលសួរថា៖ "តើមានគេសរសេរអីលើស្រោមសំបុត្រទេ?" លោកឆ្លើយថា៖ "មានតែឈ្មោះអ្នកដែលគេផ្ញើជូនទេ។ ឧទាហរណ៍ជូនចំពោះតាសាន ជាទូទៅនោះសំបុត្រទាំងអស់នេះផ្ញើជូនតាសាន"។ សំណួរថាតើនៅពេលណាមួយនោះ ក្នុងរយៈពេលណាមួយនោះ គឺថានៅក្នុងពេលណាមួយ គឺថាមុននឹងពេលដែលផ្ញើសំបុត្រទៅតាសាន នោះមានផ្ញើសំបុត្រទៅ តាឃឹម, តាគិត, តាថាយ ដែរឬទេ?

[១៥:៥៩:០៩]

**ឆ៖** បាទ អត់ដឹងទេ ក្នុងអំឡុងហ្នឹងអត់ដឹងទេបាទ។

**ស៖** តើឈ្មោះនៅលើស្រោមសំបុត្រហ្នឹងសរសេរ -- ថាវាយអង្គុលីលេខ ឬក៏សរសេរដោយដៃ?

**ឆ៖** បាទ សរសេរដោយដៃនៅលើស្រោមសំបុត្រ។

**ស៖** អ៊ីចឹងបើតាមដែលលោកឃើញតាមចន្លោះបង្អួចនោះ អ្នកណាជាអ្នកសរសេរ? ឌុចតួចអ្នកសរសេរ ឬតាអាន់ អ្នកសរសេរ ឬក៏បុគ្គលម្នាក់ផ្សេងទៀតអ្នកសរសេរ?

**ឆ៖** តាអាន់ អ្នកសរសេរ។

**ស៖** អ៊ីចឹងតើយើងអាច -- ខ្ញុំសួរថាលោកអាចស្គាល់អក្សរ តាអាន់ ទេ?

**ឆ៖** ក្នុងបច្ចុប្បន្ននេះខ្ញុំមិនដែលស្គាល់ បើកាលនៅញឹកញាប់អាចស្គាល់បាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ប្រហែលជាៗត្រូវសម្រាកនៅពេលនេះហើយ ព្រោះខ្ញុំត្រូវការបង្ហាញឯកសាររបស់គាត់ ដើម្បីឲ្យគាត់នឹកឃើញរឿងរ៉ាវ ប៉ុន្តែមើលទៅម៉ោងដូចជាជ្រេបន្តិចទៅហើយលោកប្រធាន។ ថាត្រូវសម្រាកឥឡូវ ឬក៏យ៉ាងណាលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។ សវនាការថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៤ ខែមីនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី វ៉ាន់ សឿន។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

[១៦:០១:២០]

អង្គជំនុំជម្រះសូមអរគុណចំពោះលោក វ៉ាន់ សឿន ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងនាមជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយពេលនេះលោកអាចវិលត្រឡប់ទៅកន្លែងដែលលោកស្នាក់នៅវិញបានហើយ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការជូនលោក វ៉ាន់ សឿន វិលត្រឡប់ទៅកាន់កន្លែង

ដែលគាត់ស្នាក់នៅវិញចុះ និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏កោះអញ្ជើញលោក ម៉ម រិទ្ធា ជាមេធាវីប្រឹក្សាសាក្សីមកបន្តចូលរួមប្រឹក្សាសាក្សី វ៉ាន់ សឿន ក្នុងអំឡុងពេលសាក្សីរូបនេះមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃស្អែកទៀតដែរ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*